CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ | ថ្ងៃទី០១-៣១ ខែមីនា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល | លេខ ៨៤



## បំណុលនៅតែជាហានិភ័យសម្រាប់ពលរដ្ឋដែលខ្វះការយល់ដឹង

## សេចក្តីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សី នៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្តល់ជាព័ត៌មានមកកាន់ ៖ លោករឿង ឆ័ត្រ សិរី (Fr. RoeungChatsirey )។ Tel: ០៧៧ ៨០០ ២១១ និង ០៩៦ ៣៤ ២២ ១៤៤

អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

លេខ: ០១៨/២០១៥-អក

ភ្នំពេញ, ថ្ងៃទី ១៨ កុម្ភៈ ឆ្នាំ២០១៥

បងប្អូនជាទីស្រឡាញ់ !

ថ្ងៃនេះយើងចូលក្នុងរដូវអប់រំពិសេស។ព្រះសហគមន៍ប្រទានរដូវដ៏ប្រសើរនេះដើម្បីជួយយើងឲ្យរៀបចំចិត្តគំនិតទទួល ព្រះគ្រីស្ត ដែលមានព្រះជន្មថ្មីដ៏រុងរឿង។ នៅថ្ងៃអាទិត្យទី១ ក្នុងរដូវអប់រំពិសេសខ្ញុំនឹងត្រាស់ហៅ ១៤០នាក់ ដែលកំពុងស្ដាប់ព្រះបន្ទូល លាន់ឮឡើងឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក។ ពេលនោះ យើងនឹងចាប់ផ្ដើមដំណើរប្រែចិត្តគំនិតរួមឲ្យបានជាថ្មីជាមួយគេ ដោយ មានសេចក្ដីសុខសាន្តនិងសេចក្ដីសង្ឃឹម។

ឆ្នាំនេះ ជាឆ្នាំទី២ សម្ដែងសកម្មភាពនៃមេត្តាករុណាដែលតម្រង់ទៅលើការអប់រំ និងទៅលើអគ្គសញ្ញាលើកលែងទោសព្រមទាំងប្រែគណៈកម្មាធិការសង្គហៈដែលមានគោលដៅសម្ដែងព្រះហឫទ័យមេត្តាករុណានេះ។

១). ការអប់រំប្រាជ្ញានិងចិត្តគំនិត យើងបានចាត់ចែងនូវឧបករណ៍ខ្លះសម្រាប់ជួយដល់បងប្អូនដែលមានដូចតទៅ ៖

- សៀវភៅប្រមូលសេចក្ដីបង្រៀនរបស់ខ្ញុំអំពីសេចក្ដីស្រឡាញ់តាមគម្ពីរ និងអំពីការនាំអ្នកក្រីក្រឲ្យចូលក្នុងសង្គមតាមសេចក្ដីលើកទឹកចិត្តរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងឋានៈលោកជាគ្រីស្តទូត ក្រោមចំណងជើងថា "អំណរសប្បាយមកពីដំណឹងល្អ" គឺមានគុណធម៌បួនយ៉ាងដ៏សំខាន់ (ការប្រុងប្រយ័ត្ន យុត្តិធម៌ សេចក្ដីក្លាហាន និងការចេះប្រមាណ)។ មានសេចក្ដីរាយការណ៍ថែមទៀត ពីតំបន់ទាំងបួន និងពីសហគមន៍នានា អំពីសូរសម្រែករបស់អ្នកក្រីក្រក្នុងភូមិភាគរបស់យើង។

- លិខិតរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលអញ្ជើញយើងឲ្យប្រឆាំងនឹងសកលភាវូបនិយកម្ម នៃការមិនអើពើចំពោះអ្នកដទៃ។ ព្រះសហគមន៍ត្រូវតែប្រែពីខាងក្នុង ដោយសហគមន៍យើង និងដោយយើងម្នាក់ៗប្រែចិត្តគំនិត ។
- មាន DVD បី ដកស្រង់ពីជីវប្រវត្តិ អ្នកម្ដាយថេរេសា ពីជីវប្រវត្តិលោក ជាមីយ៉ាំង និងពីគ្រូពេទ្យ។ DVD តាំងបីនោះមានរយៈពេលមើលប្រមាណ ៣០នាទី។ គំរូល្អរបស់សន្តបុគ្គលអាចជួយដាស់តឿនយើងឲ្យរស់នៅតាមឋានៈជាគ្រីស្តបរិស័ទបាន។ ឧបករណ៍ទាំងបីនោះអាចជួយអប់រំប្រាជ្ញារបស់យើងឲ្យចេះស្រឡាញ់គេ។ ប៉ុន្តែ ការសំខាន់គឺឲ្យយើងរស់នៅដោយមានបទពិសោធន៍អំពីសេចក្ដីស្រឡាញ់យ៉ាងពិតប្រាកដ តាមការរស់នៅរបស់ខ្លួន ដើម្បីបណ្ដោយឲ្យព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូផ្ទាល់អប់រំ និងណែនាំចិត្តគំនិតរបស់យើង។

តាមលិខិតរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ខ្ញុំចង់គូសសង្កត់លើចំណុចខ្លះៗ ធ្វើជាគោលក្នុង៥អាទិត្យនៃរដូវអប់រំពិសេសខាងមុខនេះគឺ៖

ក). ថ្ងៃអាទិត្យ ២២ កុម្ភៈ ២០១៥

ព្រះបិតាបានស្រឡាញ់យើងជាមុនព្រះអង្គអញ្ជើញយើងឲ្យស្រឡាញ់អ្នកដទៃដូចព្រះអង្គស្រឡាញ់គេ។ សកលភាវូបនិយកម្ម នៃការមិនអើពើដល់អ្នកដទៃបង្ខូចមនុស្សលោកដូចជាជំងឺឃ្លង់ម្យ៉ាង។ ព្រះបិតាមានព្រះហឫទ័យទុកដាក់ចំពោះមនុស្សលោក ព្រះអង្គមិនដែលមិនអើពើទេតែព្រះអង្គស្គាល់និងស្រឡាញ់យើងម្នាក់ៗ។

តើខ្ញុំភ្ញាក់រឭកអំពីព្រះបិតាស្រឡាញ់ខ្ញុំយ៉ាងណា ? តើខ្ញុំពិតជាចាត់អ្នកដទៃទុកជាបងប្អូនយ៉ាងណា?

ខ). ថ្ងៃអាទិត្យ ០១ មីនា

ព្រះសហគមន៍ប្រៀបដូចជាទ្វារចេញចូលទៅកាន់ព្រះបិតា។ ព្រះបិតាត្រាស់ហៅយើងឲ្យប្រែចិត្តគំនិតឲ្យបានជាថ្មី ដើម្បីឲ្យព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គសាយភាយក្នុងពិភពលោកទាំងមូលតាមរយៈព្រះសហគមន៍។

តើសហគមន៍យើងពិតជាសញ្ញាសម្គាល់សម្ដែងអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាចំពោះមនុស្សទាំងអស់យ៉ាងដូចម្ដេចខ្លះ?

គ). ថ្ងៃអាទិត្យ ០៨ មីនា

ក្នុងរដូវអប់រំពិសេសយើងត្រូវបណ្ដោយខ្លួនឲ្យព្រះយេស៊ូលាងជើងយើង ដើម្បីឲ្យយើងទៅជាអ្នកបម្រើដូចព្រះអង្គ។ អគ្គសញ្ញានានាសុទ្ធតែឲុចឱកាសឲ្យយើងត្រឡប់ទៅជាអ្វីដែលយើងទទួលក្នុងអគ្គសញ្ញានីមួយៗនោះ គឺឲ្យយើងទៅជាព្រះកាយព្រះគ្រីស្តឲ្យយើងលើកលែងទោស។ ល។

តើខ្ញុំបណ្ដោយខ្លួនឲ្យព្រះយេស៊ូឲ្យព្រះបន្ទូលព្រះអង្គឲ្យកាយវិការរបស់ព្រះអង្គសូនពូនខ្ញុំផ្ទាល់យ៉ាងណា ដើម្បីឲ្យខ្ញុំយកតម្រាប់តាមព្រះអង្គជារៀងរាល់ថ្ងៃក្នុងការរស់របស់ខ្ញុំ?

ឃ). ថ្ងៃអាទិត្យ ១៥ មីនា

យើងត្រូវជាមនុស្សមួយក្រុមតូចដែលចេះប្រោសប្រណីអ្នកដទៃក្នុងចំណោមមនុស្សទូទៅដែលមិនអើពើនឹងគេ។ យើងត្រូវចាកចេញពីព្រះវិហារ យើងមិនគិតតែពីប្រយោជន៍ព្រះសហគមន៍យើងប៉ុណ្ណោះទេ ដើម្បីយើងទៅជាសាក្សីអំពីព្រះបិតាកំពុងយាងមកគ្រងរាជ្យនៅចំពោះមុខអស់អ្នកដែលសង្គមមនុស្សតែងទាត់ចោល?

តើយើងត្រូវចាក់ចេញពីព្រះវិហារយើងមិនគិតតែពីប្រយោជន៍របស់ព្រះសហគមន៍យើងយ៉ាងដូចម្ដេចខ្លះ?

ង). ថ្ងៃអាទិត្យ ១៥ មីនា

ទោះបីយើងមិនអាចសង្គ្រោះមនុស្សលោកទាំងមូលដោយខ្លួនយើងផ្ទាល់បានតែយើងម្នាក់ៗ ត្រូវអធិដ្ឋានអង្វរព្រះបិតាសូមព្រះអង្គប្រទានឲ្យយើងធ្វើកិច្ចការយ៉ាងពិតប្រាកដ ដោយបង្ហាញសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃ និងបណ្ដោយខ្លួនឲ្យប្រែចិត្តគំនិតដោយឃើញអ្នកដទៃរងទុក្ខលំបាក។

យើងមានគម្រោងការសម្រាប់អាទិត្យចុងក្រោយនៃរដូវអប់រំពិសេសនេះ គឺអធិដ្ឋាន ធ្វើកិច្ចការនិងប្រែចិត្តគំនិត។ ធ្វើដូច្នេះយើងមុខជារស់នៅរួមជាមួយព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងពុំខាន។

២- អគ្គសញ្ញាលើកលែងទោស៖

វិញ្ញាណយើងពិតជាបានប្រែជាថ្មីយើងក៏ប្រែចិត្តគំនិតយ៉ាងជ្រៅ។ សេចក្ដីស្រឡាញ់បង្ហាញសកម្មភាព។ យើងត្រូវតែពង្រឹងចិត្តគំនិតយើង ក្នុងឋានៈជាសាវ័កជាមុនសិនទើបយើងមានចិត្តស្រឡាញ់តាមព្រះយេស៊ូជាគំរូរបស់យើង។

ខ្ញុំសូមអញ្ជើញសហគមន៍នីមួយៗឲ្យធ្វើអគ្គសញ្ញាលើកលែងទោសតែសូមចាប់អារម្មណ៍រៀបចំការទទួលអគ្គសញ្ញានេះតាំងពីថ្ងៃពុធ នៃពិធីរោយផេះនេះទៅ។ ដោយសារហេតុនេះ នៅពេលទទួលអគ្គសញ្ញាលើកលែងទោសម្នាក់ៗ បានរៀបចំខ្លួនតាមសេចក្ដីពិត។ យើងនឹងអាចទទួលព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណាបាន ហើយយើងក៏អាចធ្វើជាសាក្សីអំពីព្រះហឫទ័យថ្នាក់ថ្នមរបស់ព្រះអង្គចំពោះមនុស្សម្នាក់ៗបានដែរ។

៣.ការប្រែគណៈកម្មាធិការសង្ឃហៈឲ្យបានជាថ្មី

ក្នុងរដូវអប់រំពិសេសនេះខ្ញុំនឹងផ្ញើជូនបងប្អូននូវលក្ខន្តិកៈនៃគណៈកម្មការសង្ឃហៈ។ សូមបងប្អូនចាប់អារម្មណ៍អានលក្ខន្តិកៈនេះ និងរិះគិតផ្ដល់យោបល់។ ដូច្នេះ នៅពេលខាងមុខយើងអាចនឹងប្រកាសលក្ខន្តិកៈនេះជាឱឡារឹក នៅថ្ងៃ ២៤ កញ្ញា២០១៥ ក្នុងសន្និបាតអំពីសេចក្ដីស្រឡាញ់។ តែសូមកុំភ្លេចថាលក្ខន្តិកៈគ្រាន់តែជាឧបករណ៍ជួយណែនាំបងប្អូនប៉ុណ្ណោះ ប៉ុន្តែការសំខាន់ គឺសូមឲ្យបងប្អូនមានព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាហូរហៀរចេញពីក្នុងចិត្តរបស់បងប្អូនវិញ ដើម្បីឲ្យយើងអាចស្រឡាញ់អ្នកដទៃយ៉ាងខ្លាំង និងជួយសម្រាលទុក្ខគេផង។

បងប្អូនជាទីស្រឡាញ់ !

សូមបងប្អូនចាត់រដូវអប់រំពិសេសនេះទុកជាពេលព្រះបិតាប្រណីសន្ដោសដល់បងប្អូន។

សូមបណ្ដោយឲ្យព្រះបិតាមានសកម្មភាពក្នុងចិត្តបងប្អូន។

សូមជួយអង្វរព្រះបិតាប្រទានពរដល់គ្នាទៅវិញទៅមក។

សូមអង្វរព្រះបិតាប្រទានពរដល់មនុស្សលោកដែលរងទុក្ខដោយការមិនអើពើ។

សូមអង្វរព្រះបិតាប្រទានពរដល់ព្រះសហគមន៍យើងដែលមានអ្នកស្ដាប់ព្រះបន្ទូលលាន់ឮឡើង។

សូមឲ្យព្រះសហគមន៍សម្ដែងព្រះហឫទ័យស្រឡាញ់របស់ព្រះបិតារៀងរាល់ថ្ងៃដោយមិនអាក់ខានឡើយ។

សូមព្រះបិតាប្រទានពរឲ្យអស់បងប្អូននិងថែរក្សាបងប្អូនក្នុងសេចក្ដីសុខសាន្តរបស់ព្រះអង្គ។

អូលីវីយេ ឆ្មឺតអឺស្ល៊ែរ

អភិបាលរបស់បងប្អូន

# សំណង់រីកឡើងព្រោងព្រាតតែប្រឈមមុខនឹងកង្វះខាតកម្មករ



កម្មករសំណង់កំពង់ធ្វើការនៅការដ្ឋានមួយកន្លែងក្នុងទីក្រុងភ្នំពេញ។ រូបភាពៈ សហការី

វិស័យសំណង់ត្រូវបានអ្នកជំនាញការនៅក្នុងស្រុកបានអះអាងថា នឹងបន្តកើនឡើងថែមទៀត ជាពិសេសនៅតាមទីក្រុង និងតាមទីប្រជុំជន ខណៈដែលអ្នកប្រតិបត្តិករសាងសង់បានអះអាងថា វាពិតជារីកចំរើនមែន ប៉ុន្តែការដ្ឋាន នៃសំណង់មួយចំនួនអ្នកដែលកំពុងតែ សាងសង់សំណង់បានអះអាងថា ការដ្ឋានកំពុងតែប្រឈមមុខនឹងកង្វះខាតកម្មករ ។

នៅរាជធានីភ្នំពេញ ដែលគេដឹងថាគឺជាបេះដូងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ នយោបាយ របស់ប្រទេសកម្ពុជានោះ មកដល់ពេលនេះត្រូវបានប្រធានមន្ទីរ រៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី អះអាងថា វិស័យសំណង់កំពុងតែរីកចំរើនឡើងព្រោងព្រាត ដោយរហូតមកដល់ពេលនេះ មន្ទីរបានទទួលសំណើរ សុំសាងសង់ជាបន្តបន្ទាប់។

លោក ជា ស្រ៊ុន ប្រធានមន្ទីរនេះបានអះអាង នៅក្នុងសន្និបាតរបស់មន្ទីរប្រចាំឆ្នាំ កាលពីពេលថ្មីៗ កន្លងទៅនេះថា ១០ឆ្នាំ ចុងក្រោយមន្ទីរទទួលសំណើរសុំសាងសង់ សរុប ៥៦១គម្រោង ហើយមកដល់ពេលនេះ គម្រោងទាំងអស់គឺ ភាគច្រើនកំពុងតែសាងសង់។ ដោយអាគារ និងសំណង់ ដែលស្នើការសាងសង់គឺមានទាំងលក្ខណៈជាក្រុមហ៊ុន និងឯកជន។

លោកបានអះអាងបញ្ជាក់នៅក្នុងពេលនោះថា "អាគារកំពស់ពី ៥ទៅ ៩ ជាន់មាន ៣៦១អាគារ ពី ១០ ទៅ១៩ជាន់មាន ១៦៧ អាគារ ពី ២០ ទៅ២៩ មាន ២១អាគារ ពី ៣០ ទៅ ៣៩ ជាន់ មាន៨អាគារ និងពី ៤០ ជាន់ទៅគឺមាន ៤ អាគារ"។

លោកបានបញ្ជាក់បន្ថែមទៀតថា ក្រៅពីនេះ គឺបុរីវិញ នៅក្នុងទីក្រុងភ្នំពេញ មានទាំងអស់ចំនួន ៧៤បុរី។ លោកបានអះអាងថា កាលពីឆ្នាំ ២០១៤ កន្លងទៅ មន្ទីរបានទទួលគម្រោងប្លង់ ស្នើសុំអនុញ្ញាត្តសាងសង់ សរុប ៤២៩គម្រោង នៅក្នុងរង្វង់ទឹកប្រាក់ប្រមាណជាជិត ៩១៥លានដុល្លារ។ លោកបានបន្តទៀតថា នៅភ្នំពេញនេះ មានសំណង់បណ្ដោះអាសន្នប្រមាណជា ៥០៣កន្លែង ត្រូវជា ២៥.៥៣១សំណង់ ឬ ខ្នងផ្ទះមានចំនួន ២៤.៦៦៨គ្រួសារ ។

លោក ហេង សំរិទ្ធ ជាប្រជាពលរដ្ឋមួយរូបដែលកំពុងតែសាងសង់ផ្ទះមួយកន្លែងនៅក្នុងម្តុំព្រែកប្រា ខណ្ឌច្បារអំពៅ បានមានប្រសាសន៍ឲ្យដឹងថានេះគឺជាការពិតពីព្រោះពេលដែលលោកទៅដាក់ពាក្យ ស្នើសុំសាងសង់ឃើញថា មានមនុស្សជាច្រើនបានមកដាក់ពាក្យ ។

លោកបានអះអាងថា ដោយសារតែមូលហេតុដូច្នេះហើយ បានជានៅពេលនេះការដ្ឋានសំណង់ផ្ទះ របស់លោកកំពុងតែជួបប្រទះ និងកង្វះខាតកម្មករសំណង់។

លោកបានអះអាងបញ្ជាក់ថា "ផ្ទះខ្ញុំមិនជាធំទេ គឺទទឹងត្រឹម ៧បណ្តោយ ១២ ចាក់ប្លង់សេពីរសន្លឹក (ពីរជាន់) គ្រោងធ្វើតែ៦ខែ តែឥឡូវនេះ គឺសាងសង់ ជាងមួយឆ្នាំហើយនៅមិនទាន់ហើយ ដោយសារតែខ្វះខាតជាង "។

លោកបានបន្តទៀតថា ជាងមួយឆ្នាំនេះ គឺគ្រោងផ្ទះហើយ តែនៅខ្វះជាងទុយោទឹក ជាងភ្លើងតបណ្តាញ ជាងបិទការ៉ូ។លោកបានបន្តទៀតថា តាមពិតផ្ទះរបស់លោកនេះ គឺសាងសង់បានប៉ុណ្ណេះ បើមានជាង មេជាងប្រាប់ថា យ៉ាងយូរ ១ ខែ ប៉ុន្តែរកជាងល្អមិនទាន់បាន ។

លោកបានបន្តទៀតថា មេជាងប្រាប់លោកថា មានជាងតែជាជាងវៀតណាម តែលោកមិនចង់បានដោយសារតែល្បីថាជាងវៀតណាមធ្វើលឿនស្អាត តែមិនសូវជាប់ ឥចឹងក៏ចេះតែចាំៗទៅរហូតដល់ពេលបច្ចុប្បន្ននេះ។

ជុំវិញបញ្ហាជាងសំណង់នេះលោកទៀង ចំរើន ជាកម្មករសំណង់ចល័តមួយរូបដែលមកពីខេត្តព្រៃវែង បានអះអាងថា ភាគច្រើននៅពេលនេះ ទាំងអ្នកអត់ជំនាញ និងមានជំនាញ គឺគេនាំគ្នាទៅថៃអស់ហើយ ដោយទីនោះគេថា មានការងារធ្វើច្រើនហើយ បានប្រាក់ខែក៏ច្រើន ។

លោកបានអះអាងថា "ឥឡូវនេះ គេសម្រុកទៅថៃវិញ ស្ទាត់ភូមិទៀតហើយ ដើងនេះអាបងប្អូនជីដូនមួយខ្ញុំដែលធ្លាប់ដើរធ្វើសំណង់ជាមួយគ្នាតាំងពីដំបូងមក គេក៏ទៅដែរ ដោយសារតែមិត្តភ័ក្រគេ និយាយប្រាប់ថាទីនោះសប្បាយ លុយក៏ច្រើន ហើយបើចេះបូក ចេះលាប ចេះរៀបការ៉ូ ចេះតបណ្តាញទឹកដូចខ្ញុំ គឺមិនតិចជាង ៥០០ បាតទេ" ។

លោកបានអះអាងថា រូបលោកផ្ទាល់ក៏ចេះតែចង់សាកល្បងទៅហ្នឹងគេម្តងដែរ តែចេះតែខ្លាចរឿងចាញ់បោកគេ ក៏ចេះតែស៊ូទ្រាំរកការងារធ្វើនៅក្នុងប្រទេស ណាមួយ ប្រពន្ធកូនវានៅមិនទាន់រឹងដៃ រឹងជើង ខ្លាចអត់នរណាចិញ្ចឹមកូន ក៏ចេះតែធ្វើការនៅក្នុងស្រុកទៅ ។

លោកបានបន្តទៀតថា ការងារសំណង់ឥឡូវនេះ អត់ទំនេរដែរ គឺជួនដើរម៉ៅការគេធ្វើបង្គន់ ជួនតទឹកឲ្យគេជួនទៅធ្វើការសំណង់ តាមក្រុមហ៊ុនគឺមានជាបន្តបន្ទាប់ដោយយ៉ាងហោចណាស់ ក៏អាចរកប្រាក់ ចំណូល ៣០.០០០ រៀលដែរនៅក្នុងមួយថ្ងៃ ៕


**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា
រាជធានីភ្នំពេញ

**Tel/Fax : (855) 23 224 120**

**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org

**ចាងហ្វាង : លោក លី សុវណ្ណា**

Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

# យុវសិស្សនិងបុគ្គលិកសាស្រ្តាចារ្យរំពឹងថា ជំនួយនានាដល់វិស័យអប់រំនឹងមានអត្ថប្រយោជន៍ដល់ពួកគេ




រូបថត: អរិយបុត្រ

ទឹកប្រាក់ដែលមានតម្លៃប្រមាណជា ១១ លានដុល្លារអាមេរិក ត្រូវបានក្រសួងអប់រំយុវជន និង កីឡាព្រមទាំងម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ប្រកាសបើកដំណើរកាលពីពាក់កណ្តាល ខែកុម្ភៈ កន្លងទៅនេះ ។

ចំនួនទឹកប្រាក់ មួយកញ្ចប់នេះ ត្រូវបាន លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា បានមានប្រសាសន៍ថា ជាកញ្ចប់ទឹកប្រាក់ពហុជំនួយ ដែលត្រូវដំណើរការដោយមូលនិធិ ភាពជាដៃគូសម្រាប់អភិវឌ្ឍ សមត្ថភាពវិស័យអប់រំ ពី ឆ្នាំ ២០១៥-២០១៦។

លោកបានមានប្រសាសន៍ ថា ម្ចាស់ជំនួយ ពហុភាគី ដែលរួមមាន សហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ នៃប្រទេសស៊ុយអែត ហៅកាត់ថា (Sida) និង យូនីសេហ្វ នឹងចាយទៅលើការបណ្តុះបណ្តាលគ្រូថ្នាក់ទី៩និងថ្នាក់ទី១២ ។

លោករដ្ឋមន្ត្រី បានបញ្ជាក់ថា ចំពោះមូលនិធិ ភាពជាដៃគូ សម្រាប់អភិវឌ្ឍសមត្ថភាពដំណាក់កាលទី២ សម្រាប់អនុវត្តក្នុងឆ្នាំ២០១៥ និងឆ្នាំ ២០១៦នេះ ក៏មានគោលបំណងជានាកំណែទម្រង់ ដែលបានសម្រេចពីដំណាក់កាលទី១ ឲ្យកាន់តែរឹងមាំជាមួយនឹងការជួយគាំទ្របន្ថែម ទៅលើអាទិភាពថ្មីៗ នៃកំណែទម្រង់របស់ក្រសួង ព្រមទាំងធានាឲ្យមានការឆ្លើយទៅនឹង តម្រូវការបច្ចុប្បន្ន ដូចជា កំណែទម្រង់ការបណ្តុះបណ្តាលគ្រូនៅក្នុងកំរិតខាងលើ ។

លោករដ្ឋមន្ត្រី បានបន្តទៀតថា មូលនិធិនេះនឹងផ្តោតទៅលើ ការធ្វើឲ្យសម្រេចបាននូវលទ្ធផលប្រាំ ដែលរួមមាន គឺគោលនយោបាយផ្អែកតាមភ័ស្តុតាងត្រឹមត្រូវ ឈរលើមូលដ្ឋានការស្រាវជ្រាវ និងការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ, ការរៀបចំផែនការគោលនយោបាយ និងពិនិត្យតាមដានផ្តោតលើលទ្ធផល នៅគ្រប់កម្រិត, ការផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល ធ្វើឡើងផ្អែកទៅតាមគោលការណ៍សមធម៌ និងគុណភាព និង ធានាឲ្យមានគណនេយ្យភាពហិរញ្ញវត្ថុខ្ពស់ជាងមុន, ការពង្រាយ និងការគ្រប់គ្រងបុគ្គលិកកាន់តែមានប្រសិទ្ធភាព តាមរយៈយន្តការអភិវឌ្ឍសមត្ថភាពជាប្រព័ន្ធ, និង ជំរុញសមធម៌ និងគុណភាពនៃការផ្តល់សេវាអប់រំកីឡា និងការអភិវឌ្ឍយុវជនមានការកើនឡើងជាងមុន។

ជុំវិញបញ្ហាជំនួយ លើវិស័យអប់រំនេះ លោក ហ្សង់ ហ្វ្រង់ស័រកូតាំង ឯកអគ្គរដ្ឋទូតសហគមន៍អឺរ៉ុប ប្រចាំនៅកម្ពុជាដែលជាម្ចាស់ជំនួយមួយដ៏ធំសម្រាប់វិស័យអប់រំនៅកម្ពុជា បានអះអាងថា យុគសម័យពេលនេះគឺជាយុគសម័យនៃការអភិវឌ្ឍ ដូច្នេះហើយបានជា សហគមន៍អឺរ៉ុប ផ្តោតទៅលើការអប់រំ ហើយយើងបានរំលេចនូវតួនាទីដ៏សំខាន់ នៃវិស័យអប់រំ ដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ចាក់គ្រឹះ ក្នុងការធ្វើឲ្យកំណើនសេដ្ឋកិច្ច ក៏ដូចជាសុខុមាលភាពសង្គម សន្តិសុខ សមភាពយេនឌ័រ និងសន្តិភាពមានភាពទៅមុខ។

លោកបានបញ្ជាក់ ដោយសង្កត់ធ្ងន់ថា "យើងជឿជាក់ថា ការអប់រំនេះគឺជាកត្តាសំខាន់ជួយបណ្តុះបណ្តាលប្រជាពលរដ្ឋ ឲ្យចេះទទួលខុសត្រូវធ្វើឲ្យប្រទេសក្លាយទៅជា ប្រទេសដែលមានសន្តិភាព និងប្រកបទៅដោយលទ្ធិប្រជាធិបតេយ្យ"។

នេះគឺជាគោលនយោបាយ ថ្នាក់ជាតិជុំវិញការអនុវត្ត នូវកម្មវិធីកំណែទម្រង់ វិស័យអប់រំ ហើយតែងតែចាត់ទុកវិស័យអប់រំ គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេស ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មកដល់ពេលនេះ សាស្រ្តាចារ្យ និងសិស្សានុសិស្សមួយចំនួន ហាក់ដូចជា មិនបានដឹងអំពីគម្រោងនេះឡើយ ទោះបីជាគម្រោងនេះ ត្រូវបានអនុវត្ត ជាបន្តបន្ទាប់ក៏ដោយ ។

លោកសាស្រ្តាចារ្យ នៅវិទ្យាល័យបឹងត្របែកមួយរូប បានមានប្រ សាសន៍ថា លោកបានទទួលព័ត៌មានច្រើនអំពីកម្មវិធី ដែលម្ចាស់ជំនួយបានផ្តល់មកដល់ការកំណែទម្រង់ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ដែលទឹកប្រាក់ជំនួយ គឺមិនក្រោមលានដុល្លារ ទេ ប៉ុន្តែ មកដល់ពេលនេះ លោកហាក់ដូចជា មិនទទួលជ្រាបអ្វីសោះអំពីគម្រោងទាំងនេះ ។

លោកបានបញ្ជាក់ថា "តាំងពីយូរមក គឺពួកយើងធ្វើការជាគ្រូបង្រៀននេះ ដោយសារតែសតិសម្បជញ្ញៈ តែប៉ុណ្ណោះ ហើយដូចជាអត់ដែលដឹងកម្មវិធីអីនោះទេ គ្រាន់តែថា យូៗម្តងគឺគេហៅទៅសិក្ខាសាលានេះឬ សិក្ខាសាលា ដែលអង្គការ គេរៀបចំម្តងម្កាលតែប៉ុណ្ណោះ"។

លោកបានបន្តទៀតថា យើងដឹងថា មានស្ថាប័នជាច្រើន ដែលគេផ្សាយថា បានផ្តល់មូលនិធិជួយដល់វិស័យអប់រំ នៅក្នុងនោះគឺមានដូចជាសហភាពអឺរ៉ុប ធនាគារអភិវឌ្ឍអាស៊ី និង បណ្តាដៃគូនានាជាដើម ប៉ុន្តែភាគច្រើន ប្រហែលជាគេដឹង តែថ្នាក់លើទេ តែគ្រូនៅកំរិតមូលដ្ឋានដូចជាពួកខ្ញុំ គឺមិនដឹងឡើយ ។

យុវសិស្ស រុន ប្រាជ្ញា ជាសិស្សថ្នាក់ទី ១១ មួយរូប បានអះអាងថា រូបគេ ក៏ដូចជាមិនដែលបានទទួលអ្វីដែលប្លែកពីការអប់រំ នៅតាមសាលារៀនរបស់គេដែរ។

ប្រាជ្ញា បានអះអាងបញ្ជាក់ថា "ខ្ញុំដូចអត់ដឹងអីទេ មួយថ្ងៃៗ គឺដឹងថាខ្ញុំត្រូវរៀនគួរ គណិត គីមី រូបវិទ្យា ហើយជីវៈ ហើយទិញក្រដាសមេរៀនតែប៉ុណ្ណោះ បើមិនឥចឹងខ្ញុំអត់ចេះតែប៉ុណ្ណោះៗ" ៕

**ដោយអរិយបុត្រ**

# សារៈសំខាន់នៃការពិសាទឹក



រូបថតៈ លីហៀង

ទឹកជាប្រភពនៃជីវិត ដែលមនុស្សគ្រប់រូបមិនអាចខ្វះបាន សម្រាប់ការរស់នៅប្រចាំថ្ងៃ ក៏ដូចជាការចិញ្ចឹមសរីរាង្គកាយ។ ជាទូទៅ ការញ៉ាំទឹកគឺតម្រូវឲ្យបាន១,៥លីត្រ ទៅ២លីត្រក្នុង១ថ្ងៃ សម្រាប់មនុស្សពេញវ័យ។ តាមការស្រាវជ្រាវ របស់វេជ្ជសាស្ត្របានឲ្យដឹងថា ក្នុង១ថ្ងៃមនុស្សត្រូវការទឹកក្នុងរាងកាយចំនួន១លីត្រ ដើម្បីបញ្ចេញញើស ដកដង្ហើម និង ធ្វើចលនាពោះវៀន។ ហើយជាធម្មតាក្នុងអាហារ ដែលលោកអ្នកបរិភោគរៀងរាល់ថ្ងៃ មានជាតិទឹកប្រមាណ ២០%នៃទឹក ដែលលោកអ្នកទទួលទាន។

តើត្រូវពិសាទឹក ពេលណាខ្លះ? ជាទូទៅ មនុស្សគ្រប់រូបតែងគិតថា ការពិសាទឹក គឺមិនត្រូវបានរើសពេលវេលាទេ គឺអាស្រ័យតាមការស្រេករបស់លោកអ្នក។ តែបើតាមឯកសារស្រាវជ្រាវរបស់ប្រទេសជប៉ុន បានរកឃើញថា ការពិសាទឹក នៅពេលព្រឹកព្រលឹមនៅ ពេលលោកអ្នកភ្ញាក់ពីដំណេកភ្លាមចំនួន០,៦លីត្រ ឬស្មើនឹងទឹក៤កែវ (១កែវចំណុះ១៦០មីលីលីត្រ) មុនពេលដុសធ្មេញ គឺបានជួយដល់សុខភាពយ៉ាងខ្លាំង ។ ការពិសាទឹកនេះ ត្រូវបានវេជ្ជសាស្ត្រប្រទេសជប៉ុនយកមកប្រើប្រាស់ គឺបានជួយមួយផ្នែកឬ១ភាគរយនៃការព្យាបាលជំងឺមួយចំនួនដូចជា ៖ ឈឺក្បាល ឈឺរាងកាយ ប្រព័ន្ធបេះដូង ជំងឺរលាកសន្លាក់ ចង្វាក់បេះដូងដើរញាប់ ជំងឺស្កន់ ឬជំងឺឆ្កួតជ្រូក លើសជាតិខ្លាញ់ ជំងឺស្ងួត រលាកទងសួត ជំងឺរបេង រលាកស្រោមខួរក្បាល ជំងឺតម្រងនោម និងតម្រងមូត្រ ការក្អួតចង្អោរ រលាកក្រពះ រាគរូស ឫសដូងបាត ទឹកនោមផ្អែម ទល់លាមក ជំងឺភ្នែកគ្រប់បែបយ៉ាង ស្បូន ជំងឺមហារីក និង ដំណើរវដ្ដរដូវ ជំងឺត្រចៀក ច្រមុះ និងបំពង់ក។

ក្រៅពីពិសាទឹក ពេលភ្ញាក់ពីដំណេក តើលោកអ្នក ត្រូវធ្វើអ្វីបន្ថែមទៀត?

១. បន្ទាប់ពីពិសាទឹក០,៦លីតរួច ហើយលោកអ្នកអាចដុសធ្មេញ ប៉ុន្តែកុំពិសា ឬបរិភោគអ្វីមួយក្នុងរយៈពេល ៤៥នាទី។

២. បន្ទាប់ពីរយៈពេល ៤៥នាទី លោកអ្នកអាចពិសា ឬបរិភោគដូចសព្វដង។

៣. រយៈពេល១៥នាទី នៃអាហារពេលព្រឹក អាហារថ្ងៃត្រង់ និង អាហារល្ងាច កុំពិសា ឬបរិភោគអ្វីមួយរយៈពេលពីរម៉ោង។

៤. អ្នកមានវ័យចាស់ ឬមានជំងឺមិនអាចបរិភោគទឹកបួនកែវ នៅពេលចាប់ផ្ដើមបានឡើយ អាចចាប់ផ្ដើមពិសាបន្តិចម្ដងៗ និងបង្កើនការញ៉ាំទឹកជាសន្សឹមៗ រហូតដល់បួនកែវក្នុងមួយថ្ងៃ។

ឯកសារស្រាវជ្រាវដដែល បានបង្ហាញថា ការពិសាទឹកនេះ អាចជួយកាត់បន្ថយ គ្រប់គ្រង និងព្យាបាលនូវជំងឺសំខាន់ៗមួយចំនួន ក្នុងរយៈពេលដូចជា ៖ សម្ពាធឈាមខ្ពស់ (៣០ថ្ងៃ) ជំងឺក្រពះ (១០ ថ្ងៃ) ទឹកនោមផ្អែម (៣០ថ្ងៃ) ការទល់លាមក (១០ ថ្ងៃ) មហារីក (១៨០ ថ្ងៃ) របេង (៩០ ថ្ងៃ) អ្នកជំងឺរលាកសន្លាក់គួរតែធ្វើតាមវិធីព្យាបាលខាងលើនេះ ត្រឹមរយៈពេលបីថ្ងៃប៉ុណ្ណោះ ក្នុងសប្ដាហ៍ដំបូង និងចាប់ពីសប្ដាហ៍ទីពីរតទៅជាប្រចាំថ្ងៃ៕

# កម្មវិធីខួបកំណើតទី២០០ឆ្នាំរបស់សន្តយ៉ូហាន បូស្កូ



លោកអភិបាលកំពុងចូលរួមពីធីខួបកំណើតទី២០០ឆ្នាំ របស់សន្តយ៉ូហានបូស្កូ។ រូបថតៈ សុធីរិទ្ធិ

ក្រុមគ្រួសារ សាលេស៊ានដុនបូស្កូ និង សិស្សានុសិស្សទាំងឡាយ នៃសាលាដុនបូស្កូ ទូទាំងព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធខួបកំណើតទី២០០ឆ្នាំរបស់សន្តយ៉ូហានបូស្កូដែលជាស្ថាបនិកក្រុមសាលេស៊ាន ហើយគេតែងតែចងចាំថា ជាមនុស្សម្នាក់ដែលបូជាជីវិតរបស់ខ្លួន ដើម្បីបម្រើយុវជនដែលគ្មានទីពឹង។

កម្មវិធីនេះ រៀបចំឡើងនៅថ្ងៃទី៣០ ខែមករា ក្រោមអធិបតីភាពរបស់សម្ដេចរាជបុត្រី ព្រះអនុជនរោត្តមអរុណរស្មី លោក ចន វីសឺ ជាប្រធានមូលនិធិដុនបូស្កូកម្ពុជា លោកបូជាចារ្យ សូតូ រ៉ូអែល ជាប្រធានប្រតិបត្តិដុនបូស្កូកម្ពុជា តំណាងស្ថាប័នរដ្ឋ និងអង្គការនានាសរុបប្រមាណជាង ១០០០ នាក់ នៅសាលាបណ្ដុះបណ្ដាលបច្ចេកទេសដុនបូស្កូភ្នំពេញថ្មី ក្នុងភូមិប្រៃស សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ក្រុងភ្នំពេញ។

ក្នុងនោះសម្ដេចព្រះអនុជត្រី បានមានព្រះបន្ទូល គាំទ្រសកម្មភាពអប់រំរបស់សាលាដុនបូស្កូ និង សូមឲ្យសាលានេះ យកចិត្តទុកដាក់បន្ថែមលើការពង្រឹងសមត្ថភាពឲ្យមានកំរិតកាន់តែខ្ពស់ឡើង ដល់សិស្សនិស្សិតឲ្យក្លាយជាមនុស្សពេញលេញ មានសីលធម៌ វប្បធម៌ និង ចេតនារម្មណ៍ល្អប្រពៃ ដោយមានការចូលរួមប្រកួតប្រជែងចំណេះដឹង និង ជំនាញក្នុងសហគមន៍អាស៊ាន និងឈានទៅចូលរួមប្រកួតប្រជែងកម្រិតអន្តរជាតិ។

ឆ្លៀតក្នុងឱកាសនេះ លោក ចន វីសឺ មានប្រសាសន៍ថា សាលាដុនបូស្កូ បានចូលមកកម្ពុជា ២៤ឆ្នាំហើយ ក្នុងគោលបំណងក្លាយទៅជាសាលារៀន និង ជាផ្ទះដើម្បីរៀបចំជួយដល់អ្នក ដែលលំបាកបំផុតនៅក្នុងសង្គម ដើម្បីកសាងយុវជនយុវនារីឲ្យចេះទទួលខុសត្រូវ និងក្លាយជា ពលរដ្ឋល្អសម្រាប់ប្រទេសជាតិ និង ព្រះជាម្ចាស់ ដោយមានទស្សនវិស័យ របស់លោកឪពុកបូស្កូ គឺប្រព័ន្ធការពារ ដែលផ្អែកលើការស្រឡាញ់ចិត្តសប្បុរស មានហេតុផល និង សាសនា ព្រោះមនុស្សវ័យក្មេងត្រូវការចំណេះដឹង សេចក្ដីស្រឡាញ់ និងអត្ថន័យនៅក្នុងជីវិត។

លោកឪពុកបូស្កូ កើតថ្ងៃទី ១៦ សីហា ១៨១៥ និងទទួលមរណភាពនៅថ្ងៃទី៣១ មករា១៨៨៨។ ថ្ងៃទី០២ មិថុនា ១៩២៩ សម្ដេចប៉ាបពិយ៉ូសទី ១១ បានប្រកាសជាឱឡារិកថា ដុនបូស្កូ ជាជនដែលមានសុភមង្គល ហើយបានប្រកាសជាសន្តបុគ្គលនៅថ្ងៃទី១ មេសា ១៩៣៤ ។

**ដោយដាលីស**

# កសិកម្មសរីរាង្គនាំមកនូវអត្ថប្រយោជន៍បន្ថែមមួយចំណែកសម្រាប់កសិករ


លោក ឈឹម ផល្លីបុត្រ កំពុងតែធ្វើបទសម្ភាសន៍។ រូបថតៈ អរិយបុត្រ

*វិស័យកសិកម្មនៅកម្ពុជា ថ្វីត្បិតតែមិនទំនើប ប៉ុន្តែការដាំដុះតាមគោលការណ៍ធម្មជាតិគឺនៅមានកំរិត ខណៈដែលគោលការណ៍ដាំដុះតាមធម្មជាតិនេះ ត្រូវបានគេអះអាងថា អាចឲ្យកសិករ ទទួលបានតម្លៃបន្ថែមមួយចំណែក ដូច្នេះដើម្បីឲ្យយល់ច្បាស់ថា តើការដាំដុះតាមគោលការណ៍ ធម្មជាតិនោះយ៉ាងណា* ***អ្នកនាំសារ*** *សូមណែនាំឲ្យជួប* ***លោក ឈឹម ផល្លីបុត្រ*** *អ្នកសំរបសំរួល សមាគមកសិកម្មសរីរាង្គកម្ពុជា ។*

**អ្នកនាំសារ ៖** តើហេតុអ្វី បានជាសមាគម ជំរុញការយកចិត្តទុកដាក់លើកសិកម្មសរីរាង្គនៅកម្ពុជា?

**លោកឈឹមផល្លីបុត្រ៖** គោលបំណងរបស់សមាគមនេះគឺថា ទីមួយធ្វើកសិកម្ម តាមគោលការណ៍ធម្មជាតិពោល គឺមិនប្រើប្រាស់នូវសារធាតុគីមី ដូច្នេះយើងក៏បង្កើតសមាគមនេះឡើង ដើម្បីជួយជំរុញសហគមន៍កសិករ គាត់ផ្តោតលើដំណាំកសិកម្មសរីរាង្គ ដែលជាផលិតផលមួយអាចមានតម្លៃមួយសមរម្យនៅលើទីផ្សារ ។ ជាធម្មតា ផលិតផលនៃដំណាំសរីរាង្គគឺមានតម្លៃ ប្រសើរជាងផលិតផលដែលប្រើសារធាតុគីមី។ ឧទាហរណ៍ដូចជា ស្រូវដែលយើងកំពុងតែធ្វើជាមួយនឹងកសិករ៨សហគមន៍នៅខេត្តព្រះវិហារ គឺតម្លៃរបស់វាខ្ពស់ជាងស្រូវធម្មតាប្រមាណជា ២០០រៀល នៅក្នុងមួយគីឡូ ។

**អ្នកនាំសារ៖** យើងតែងតែឮពាក្យថា កសិកម្មសរីរាង្គៗ តើអ្វីទៅដែលគេហៅថាកសិកម្មសរីរាង្គ?

**លោកឈឹម ផល្លីបុត្រ ៖** ជាការដាំដុះនូវដំណាំដែលមិនប្រើប្រាស់សារធាតុគីមី ដែលនាំឲ្យមានផលប៉ះពាល់ទៅដល់បរិស្ថានសង្គម។

**អ្នកនាំសារ ៖** តើស្រូវសរីរាង្គនិងស្រូវធម្មតា វាខុសគ្នាយ៉ាងម្តេច ហើយតើមូលហេតុអ្វី បានជាស្រូវសរីរាង្គមានតម្លៃខ្ពស់ជាង?

**លោក ឈឹម ផល្លីបុត្រ ៖** ស្រូវសរីរាង្គ និងស្រូវធម្មតា ឬ អង្ករធម្មតា និង អង្ករសរីរាង្គគឺ វាខុសគ្នានៅត្រង់ថា អង្ករឬស្រូវមួយដែលមានសញ្ញាប័ត្រ និង អត់សញ្ញាប័ត្រ។ ឧទារណ៍អង្ករដំរួល បើសិនជាអត់សញ្ញាប័ត្រ គឺគេមិនហៅថា ជាអង្ករ ឬជាស្រូវសរីរាង្គបានទេ ។

**អ្នកនាំសារ ៖** តើលោក អាចកំណត់ថា មួយណាជាអង្ករសរីរាង្គ និង មួយណាជាអង្ករធម្មតាយ៉ាងណា?

**លោក ឈឹម ផល្លីបុត្រ ៖** នេះគឺជាការពិត ប្រសិនបើយើងយកអង្ករមកដាក់នៅលើដៃ យើងមិនអាចដឹងបានទេ ប៉ុន្តែបើសិនជាយើងយកអង្ករនេះទៅវេចខ្ចប់គឺយើងអាចដឹងតាមវិធីនេះ ។ ដោយសារតែនៅលើកញ្ចប់ គឺមានសញ្ញាបញ្ជាក់ ហើយអ្នកដែលប្រើប្រាស់ គ្រាន់តែមើលឃើញផ្លាកសញ្ញានេះគឺគេដឹង។

**អ្នកនាំសារ ៖** យើងអាចដឹងបានថា មួយណាជាផលិតផលសរីរាង្គ និង ធម្មតាដោយវិធីណា បើគ្មានការវេចខ្ចប់?

**លោក ឈឹម ផល្លីបុត្រ ៖** ជាការពិតសម្រាប់នៅទីផ្សារ នៅក្នុងស្រុកយើង គឺអាចមានបញ្ហាបែបនេះ ដោយសារតែយើង នៅមិនទាន់មានឯកសារដែលជាបទដ្ឋានត្រឹមត្រូវ ដើម្បីធានាផលិតផលសរីរាង្គនេះ នៅឡើយទេ ប៉ុន្តែនៅអាមេរិក នៅសហគមន៍ អឺរ៉ុបដែលជាទីផ្សារ នៃផលិតផលសរីរាង្គរបស់យើង គឺគេមានច្បាប់ទម្លាប់តឹងហើយការក្លែងបន្លំ គឺអាចមានបញ្ហា ។ ពីព្រោះគេមានប្រព័ន្ធ និង មានលទ្ធភាពខ្ពស់ លើការត្រួតពិនិត្យផលិតផលទាំងនេះ។

**អ្នកនាំសារ ៖** លោកមានប្រសាសន៍ថា ផលិតផលសរីរាង្គ ជាពិសេសគឺអង្ករយើង គឺមានទីផ្សារនាំចេញទៅក្រៅ ដូច្នេះមកដល់ពេលនេះ តើនៅក្នុងចំណោមអង្ករដែលយើងនាំចេញសរុបកាលពីឆ្នាំទៅគឺអង្ករសរីរាង្គមានប៉ុន្មានភាគរយ ?

**លោក ឈឹម ផល្លីបុត្រ ៖** យើងមិនទាន់នាំចេញអង្ករសីរាង្គ នៅក្រោមផ្ទៃរបស់សមាគមបាននៅឡើយទេ ប៉ុន្តែឆ្នាំ ២០១៥ នេះ គឺយើងនឹងអាចបានដោយបរិមាណ នៃការនាំចេញ គឺប្រមាណជា ១៥០០ តោន ប៉ុន្តែជារួមភាគរយ នៃការនាំចេញអង្ករសរីរាង្គទៅទីផ្សារនាំចេញក្រៅប្រទេស មកដល់ពេលនេះ គឺតិចនៅឡើយទេធៀបនឹងបរិមាណអង្ករដែល យើងអាចនាំចេញបានគឺ ប្រមាណជា ០,០១ ភាគរយប៉ុណ្ណោះ ។

**អ្នកនាំសារ ៖** តើមូលហេតុអ្វីបានជាបរិមាណនាំចេញអង្ករសរីរាង្គ បានតិចបែបនេះ ?

**លោក ឈឹម ផល្លីបុត្រ ៖** ហេតុផលគឺថា វាមិនមែនថា វាមិនមែនជាផលិតផលដែលងាយ នឹងធ្វើបានទេ គឺលុះត្រាតែអ្នកផលិតនោះមានឆន្ទៈស្មោះត្រង់ ហើយមោះមុត នៅក្នុងការងារហ្នឹង ហើយក៏ត្រូវការនូវបរិស្ថានមួយដែលជាក់លាក់ផងដែរ ជាក់ស្តែងកន្លែងមួយ ដែលយើងធ្លាប់ប្រើគីមី ហើយយើងទៅធ្វើជាកសិកម្មសរីរាង្គភ្លាមគឺមិនបានទេ ។

**អ្នកនាំសារ ៖** ជាទូទៅផ្នត់គំនិតកសិករភាគច្រើន គឺជិតដាមដោយសារតែរឿងប្រើគីមីនេះច្រើន ដូច្នេះ តើយើងត្រូវធ្វើដូចម្តេច ដើម្បីឲ្យប្រាកដថា កសិករយើងមិនប្រើគីមី?

**លោក ឈឹម ផល្លីបុត្រ ៖** ការផ្លាស់ប្តូរផ្នត់គំនិតកសិករ គឺពិតជាលំបាកមែន ប៉ុន្តែកម្ពុជា នៅមានតំបន់ដែលមិនទាន់ប្រើ និង មានតំបន់ដែលមានប្រើតិចតួច គឺយើងអាចធ្វើបាន ដោយណែនាំកសិករ ហើយសំខាន់ គឺថាការទាញយកតម្លៃបន្ថែម ។

**អ្នកនាំសារ ៖** លោកបានមានប្រសាសន៍មិញនេះថា ផលិតផលសរីរាង្គ ជាពិសេសគឺអង្ករ គឺបានថ្លៃជាងអង្ករធម្មតានោះ២០០រៀលប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ២០០ រៀលនេះហាក់ដូចជាតិចណាស់ នៅក្នុងការជំរុញនឹងលើកទឹកចិត្តកសិករធ្វើកសិកម្ម តាមគោលការធម្មជាតិ ដោយសារតែនេះ គឺជាកិច្ចការដ៏លំបាក?

**លោក ឈឹម ផល្លីបុត្រ ៖** យើងស្តាប់ទៅគោលការណ៍ គឺពិតជាមានភាពស្មុគស្មាញ ប៉ុន្តែបើយើងអនុវត្តជាក់ស្តែង គឺមិនលំបាកដូចនៅក្នុងក្រដាសពេកឡើយ។ ធម្មតា កសិករគឺគាត់ធ្វើតាម គោលការណ៍ធម្មជាតិ ហើយពោលគឺយើងគ្រាន់តែ ណែនាំឲ្យគាត់មានកំណត់ហេតុ ច្បាស់លាស់ ហើយ យើងបង្រៀនគាត់តាមកិច្ចការជាជំហានៗ។ ការងារទាំងនេះ មិនលំបាកទេ គឺដោយទាមទារត្រឹមតែទម្លាប់។ នៅពេលដែលគាត់ធ្លាប់ធ្វើមួយដង គឺវាលែងជាការងារ លំបាកទៀតហើយ៕

**ដោយអរិយបុត្រ**

Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉ារីតាស់អាស៊ី (RVA) ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**
**ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**

ពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០គីឡូហឺតស៍ ត្រូវនឹងកម្ពស់២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉ារីតាស់អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។

# អ្នកជួលផ្ទះសុំឲ្យរដ្ឋគិតគូរការតភ្ជាប់បណ្តាញអគ្គិសនីមួយគីឡូវ៉ាត់ម៉ោង៦១០រៀលដូចគ្នា



រូបថត: លីហៀង

ក្រុមកម្មករ និងកម្មការនី បុគ្គលិកអង្គការ និងអ្នកដែលប្រកបរបរផ្ទះជួលដែលកំពុងតែរស់នៅតាមផ្ទះជួលនៅរាជធានីភ្នំពេញ ស្នើសុំឲ្យអាជ្ញាធរគិតពីការតភ្ជាប់បណ្តាញអគ្គិសនី របស់រដ្ឋមួយ គីឡូវ៉ាត់ម៉ោង ៦១០ រៀលដូចៗគ្នាទាំងអស់។

លោក វិត សំរាំង ជាអ្នករត់ម៉ូតូឌុបចល័ត ដែលបច្ចុប្បន្ននេះ គាត់សព្វថ្ងៃ គឺកំពុងតែរស់នៅក្នុងបន្ទប់ផ្ទះជួលមួយកន្លែង នៅម្តុំទល់មុខព្រឹទ្ធសភា ជាមួយនឹងនារីឡង់សេនារីខាំ៉ាអូខេ បុគ្គលិករាជការ អង្គការជាច្រើន បានរអ៊ូថា រស់នៅក្នុងផ្ទះជួលដូចគ្នា ហេតុអ្វីបានជា រដ្ឋគិតគូរតែកម្មករមួយក្រុមបែបនេះ វាគួតែគិតគូទាំងអស់។

លោកបានបញ្ជាក់ថា "យើងជាអ្នករស់នៅផ្ទះជួលដូចគ្នា គួរណាស់រដ្ឋគិតគូពួកយើងទាំងអស់គ្នា"។

លោក សុខ ចំណារ ជាមន្ត្រីអង្គការក្រៅរដ្ឋាភិបាលមួយ បានមានប្រសាសន៍ថា សព្វថ្ងៃនេះ លោកកំពុងតែស្នាក់នៅបន្ទប់ជួលមួយកន្លែងនៅម្តុំទឹកល្អក់ ជាមួយនឹងប្អូនពីរនាក់ដែលកំពុងតែរៀន ដោយមួយបន្ទប់លោកចំណាយ ទាំងថ្លៃបន្ទប់ ថ្លៃទឹក និង ថ្លៃភ្លើង មួយខែអស់ក្បែរៗនឹង ១០០ ដុល្លារដែរ ដោយថ្លៃបន្ទប់អស់ ៦៤ដុល្លារ និង ថ្លៃភ្លើង ៦០.០០០ ទៅ ៧០.០០០ រៀល ហើយថ្លៃទឹកវិញ គឺ ២០.០០០ ទៅ ៣០.០០០ រៀលដែរ ។

លោកបានបន្តទៀតថា លោកក៏ស្នើសុំ ឲ្យរដ្ឋយកចិត្តទុកដាក់គិតគូរដល់ពួកគាត់ដែលរស់នៅផ្ទះជួលទាំងអស់ដូចៗគ្នា។

លោកបានបញ្ជាក់ថា "ធ្វើការនៅអង្គការបានប្រាក់ខែ ត្រឹមតែ៣៥០ ដុល្លារនៅក្នុងមួយខែ សង្ឃឹមអីនឹងមានលុយសល់ទិញផ្ទះ បង្កើតគ្រួសារដូចគេ បើលុយបើកម៉ោអស់ៗ តែរាល់ខែបែបនេះ"។

លោកបានបញ្ជាក់ បន្តទៀតថា "បើបានប្រើទឹកមួយម៉ែត្រគីប១១០០ រៀល ហើយភ្លើងមួយគីឡូ ៦១០ រៀលដូចគេ ខ្ញុំអាចសន្សំបាន ១០ ទៅ១៥ ដុល្លារអីដែរ នៅក្នុងមួយខែ ខណៈដែលឥឡូវនេះ បើកប្រាក់ខែម៉ោអស់អាលីង ជួនកាលខ្ចីគេចាយដើមខែទៀតក៏មានដែរ"។

បើតាមការអះអាង របស់លោក ចំណារ តម្លៃភ្លើងអគ្គិសនី ដែលលោកកំពុងតែប្រើនៅពេលនេះ គឺមួយគីឡូវ៉ាត់ម៉ោងថ្លៃ១.៥០០រៀល ហើយទឹក គឺមួយគូប គឺ ២.៥០០ រៀល ។

អ្នកនាង ហេង ផន ជានារីដែលកំពុងតែប្រកបរបរ នៅក្នុងសេវាកម្មកំសាន្តបានអះអាងថា ជីវិតរស់នៅផ្ទះជួល គឺអ្នកនាង និងកម្មការនីរោងចក្រកាត់ដេរមិនខុសគ្នាទេ ហេតុអ្វីបានជារដ្ឋាភិបាល គិតតែកម្មករកាត់ដេរទៅវិញ។

អ្នកនាងបានបញ្ជាក់ថា "អ្នកប្រើភ្លើងថ្លៃ ទឹកថ្លៃ មិនមែនតែកម្មករកាត់ដេរឯណា ពួកយើងក៏ប្រើថ្លៃដែរ"។

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៥ កន្លងទៅនេះ ជាមួយនឹងថវិកាប្រមាណជា ២ លានដុល្លារ អគ្គិសនីកម្ពុជា បានចុះយុទ្ធនាការតភ្ជាប់ចរន្តអគ្គិសនីតំលៃ៦១០រៀល ដែលជាអត្រាថ្លៃអនុគ្រោះ ជូនដល់អ្នកប្រើប្រាស់ ក្រោម៥០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ នៅខណ្ឌចំនួន៣ ឫស្សីកែវ ដង្កោ និងមានជ័យ។

លោក កែវ រតនៈ ប្រតិភូទទួលបន្ទុកអគ្គនាយកអគ្គិសនីកម្ពុជាបានប្រាប់អ្នកកាសែត កាលពីពេលថ្មីៗនេះថា រាជរដ្ឋាភិបាលគិតគូ ទាំងអស់គ្នា ប៉ុន្តែនេះគឺជាជំហានដំបូង ដោយនៅដំណាក់កាលដំបូងនេះ គឺមានតែ ៤ សង្កាត់ទេ នៅក្នុងខ័ណ្ឌទាំងបីនេះ ពោលគឺ នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ, សង្កាត់ចាក់អង្រែលើ និងចាក់អង្រែក្រោម នៅខណ្ឌមានជ័យ និង សង្កាត់ដង្កោ នាខណ្ឌដង្កោ ដោយទីនោះ គឺមានបងប្អូនកម្មករ និងកម្មការនីរោងចក្រច្រើន។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍កាលពីថ្ងៃទី១០ ខែកុម្ភៈកន្លងទៅនេះថា នៅពេលនេះក្នុងចំណោមបន្ទប់ផ្ទះជួល សរុបប្រមាណ ៩០.៤៧៨បន្ទប់នោះ គឺអគ្គិសនីកម្ពុជាបានតភ្ជាប់ភ្លើងតម្លៃថោកនេះបានជាង៨.០០០បន្ទប់ហើយ ។

សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសឱ្យអាជ្ញាធររាជធានីភ្នំពេញ អគ្គិសនីកម្ពុជា រួមទាំងអាជ្ញាធរគ្រប់ជាន់ថ្នាក់បន្តដំណើរការ តភ្ជាប់បណ្តាញភ្លើងអគ្គិសនី ដល់បន្ទប់ផ្ទះជួលរបស់សិស្សនិស្សិត ប្រជាពលរដ្ឋនៅទូទាំងប្រទេសពិសេសកម្មករកម្មការិនី នៅភ្នំពេញតែម្តង ។

សម្តេចតេជោ ហ៊ុន សែន ក៏បានដាក់បទបញ្ជាផ្ទាល់មាត់ ទៅកាន់អភិបាលរាជធានីភ្នំពេញ និងលោកទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីធ្វើការជាមួយម្ចាស់ផ្ទះជួល ក្នុងការបញ្ចុះតម្លៃទឹក ដែលកន្លងមកម្ចាស់ផ្ទះជួលយកថ្លៃដូចថ្លៃភ្លើងដែរ គឺលើសពីតម្លៃរបស់រដ្ឋ។

សម្តេចហ៊ុនសែនបានប្រកាសថា ឥឡូវនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្មលក់ទឹក ក្នុងតម្លៃថេរមួយទៅឱ្យម្ចាស់ផ្ទះ១.០៣០ រៀលក្នុងមួយម៉ែត្រគូប ហើយម្ចាស់ផ្ទះលក់ទៅឱ្យអ្នកជួលបន្ទប់ត្រឹម តែតម្លៃ១.១០០ រៀលទៅ១.២០០រៀលបានហើយ។

ចាប់ពីថ្ងៃទី២៩ មករា រហូតដល់ថ្ងៃទី៩កុម្ភៈ អគ្គីសនីកម្ពុជា បានអះអាងថា មន្ត្រីជំនាញបានតបណ្តាញអគ្គីសនី ទៅកាន់ផ្ទះជួល បានជាង ៨.០០០បន្ទប់ ក្នុងចំណោមបន្ទប់ផ្ទះជួលសរុបប្រមាណ ៩០.៤៧៨បន្ទប់នោះ។ ហើយប្រសិនបើ ការងារតចរន្តនេះលឿនដូចជាថ្ងៃដំបូង រួមទាំងមានកិច្ចសហការ ល្អពីម្ចាស់ផ្ទះជួលផងនោះ ការងារភ្ជាប់បណ្តាញនេះនឹងអាចត្រូវបញ្ចប់ មុនរយៈពេល ២ ខែ ៕

**ដោយអរិយបុត្រ**

# ព្រះសហគមន៍ចំការទៀងធ្វើបុណ្យផ្កាប្រមូលបច្ច័យសង់សាលាឆាន់នៅវត្តអង្គមន្ត្រី



កាលពីរសៀលថ្ងៃច័ន្ទ ទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ កន្លងទៅ គណៈ-កម្មការព្រះសហគមន៍កាតូលិក ចំការទៀងបានដង្ហែ បុណ្យផ្ការស្មើសាមគ្គីទៅវត្តអង្គមន្ត្រី ក្នុងខេត្តតាកែវ។

ពិធីនោះ មានការអញ្ជើញចូលរួមជាអធិបតី ពីសំណាក់លោកអភិបាល អូលីវីយេ ឆ្មីតហាស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។

ថ្លែងនៅក្នុងពិធីនោះលោកអភិ-បាលអូលីវីយេ បានមានប្រសាសន៍ថានៅថ្ងៃនេះព្រះសហគមន៍កាតូលិកចំការទៀង រួមជាមួយបងប្អូនគ្រីស្តបរិស័ទ មានអំណរសប្បាយរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមជាមួយ បងប្អូនពុទ្ធបរិស័ទនៅវត្តអង្គមន្ត្រី ក្នុងពិធីបុណ្យផ្ការស្មើសាមគ្គី ដើម្បីប្រមូលបច្ច័យ សម្រាប់ការសាងសង់សាលាឆាន់នេះ ។

លោកអភិបាល មានប្រសាសន៍បន្តថាយើងត្រូវជួយគ្នាទៅវិញទៅមក ដោយយើងដឹងថា ទាំងខាងពុទ្ធសាសនា និងគ្រីស្តសាសនា យើងរួមគ្នាសហការគ្នា និងចងសម្ពន្ធមេត្រីភាពរវាងគ្នានិងគ្នា។ សម្រាប់ព្រះសហគមន៍ចំការទៀងយើងមានទំ-នាក់ទំនងគ្នាយ៉ាងល្អ ជាយូរឆ្នាំហើយជាមួយវត្តអង្គមន្ត្រីនេះ។ ពេលនេះជាឱកាសមួយ ដើម្បីបង្ហាញឲ្យយើងឃើញថា យើងជាក្រុមគ្រួសារតែមួយដោយចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងសហគមន៍យើង ។

ព្រះតេជគុណ អេម ប៊ុននី ចៅអធិការវត្តអង្គមន្ត្រី បានសង្ឃដិកាឲ្យដឹងថា គោលការណ៍នៃការអប់រំ គឺគ្រប់សាសនាទាំងអស់ តែងតែស្វែងរកនូវធម៌អហិង្សា មិនថាតែព្រះពុទ្ធសាសនា ឬគ្រីស្តសាសនានោះទេ គឺគ្រប់សាសនាទាំងអស់ប្រកាន់យកនូវការកសាងសុខសន្តិភាព ដើម្បីភាពសុខដុមរមនារវាងគ្នានិងគ្នា។ ពិធីនេះសបញ្ជាក់ឲ្យឃើញថា ទំនាក់ទំនងរវាងព្រះសហគមន៍កាតូលិក និងព្រះពុទ្ធសាសនារួមគ្នា ក្នុងន័យកសាងសាមគ្គីភាព និងភាពសុខសាន្តនៅក្នុងសង្គម ។

លោក អ៊ុក ភឿន ប្រធានគណៈកម្មការវត្តអង្គមន្ត្រី បានមានចំណាប់អារម្មណ៍ថា ក្នុងនាមគណៈកម្មការអាចារ្យវត្តអង្គមន្ត្រី និងក្នុងនាមប្រជាពលរដ្ឋ ចំណុះជើងវត្តអង្គមន្ត្រី សូមថ្លែងអំណរគុណ ចំពោះលោកអភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ ដែលតែងតែគាំទ្រ និងជួយកសាងសាលាឆាន់នេះ។

លោកបានបញ្ជាក់ថា ការចងសម្ព័ន្ធមេត្រីភាព រវាងគ្រីស្តសាសនា និងព្រះពុទ្ធសាសនា គឺល្អណាស់ ដែលទាំងពុទ្ធសាសនា និងគ្រីស្តសាសនា យើងមិនប្រកាន់គ្នាទៅវិញទៅមក ដោយយើងមានទិសដៅតែមួយ ក្នុងការកសាងសន្តិភាព និងយុត្តិធម៌ ដើម្បីភាពរីកចម្រើនក្នុងការសាមគ្គីគ្នារវាងគ្នានិងគ្នា ។

នេះមិនមែនជាលើកទីមួយទេ ដែលព្រះសហគមន៍កាតូលិក បានចូលរួមចមណែកក្នុងកាសាង ក្នុងវត្តអង្គមន្ត្រីនេះគឺមានជាហូរហែរ។ បុណ្យផ្កាដែល ចូលរួមលើកនេះពីព្រះសហគមន៍កាតូលិក មានចំនួន ជាង ២៥០០ ដុល្លាអាមេរិក។

## ជនបរទេសសកម្មជនការពារបរិស្ថាននៅអារ៉ែងត្រូវឃាត់ខ្លួននិងបញ្ជូនចេញពីប្រទេស

លោក អាឡិចហ្សង់ ដ្រូហ្គន់ហ្សេលេសដេវីដសុន ( Alexandro Gon-zalesDavidson ) ជនជាតិអេស្ប៉ាញ និង ជាអនុប្រធានអង្គការមាតាធម្ម-ជាតិត្រូវបានអាជ្ញាធរកម្ពុជាឃាត់ខ្លួនកាលពីរសៀល ថ្ងៃទី២៣ ខែកុម្ភៈ និងបានបញ្ជូនចេញទៅក្រៅប្រទេសនៅថ្ងៃដដែល ។

លោក អាឡិច ដែលជាជនបរទេសនិយាយ ភាសារខ្មែរច្បាស់ក្រោយពីចូលមកកម្ពុជា ប្រមាណជា ១០ឆ្នាំ ត្រូវបានអាជ្ញាធរឃាត់ខ្លួននៅភោជនីយដ្ឋានមួយ ខាងត្បូងផ្សាររាត្រីមាត់ទន្លេ ក្នុងរាជធានីភ្នំពេញ។

លោកត្រូវបានចាប់ខ្លួន តាមសេចក្តីប្រកាសលេខ២២៨៧ ប្រ.ក របស់ក្រសួងមហាផ្ទៃចុះថ្ងៃដដែល ក្រោយពេលដែលលោក អស់សុពលភាពរស់នៅស្របច្បាប់ នៅកម្ពុជាកាលពីថ្ងៃទី២០ ខែដដែលនោះ ។

លោកត្រូវបានគេដឹងថា គឺជាសកម្មជន ការពារបរិស្ថានមួយ នៅភូមិភាគនិរតី ប្រឆាំងនឹងគម្រោងកសាងទំនប់ វារីអគ្គិសនីមួយកន្លែងនៅជួរភ្នំក្រវាញ ក្រោយពេលដែលរាជរដ្ឋាភិបាល កំពុងតែសិក្សាអំពីលទ្ធភាពកសាងទំនប់វារីអគ្គិសនីនៅទីនោះ ៕

## ក្រសួងបរិស្ថានប្រ-កាសតាមដានក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចចំនួន១៧

ក្រុមហ៊ុនចំនួន១៧ ត្រូវបានក្រ-សួងបរិស្ថាន ប្រកាសដាក់នៅក្រោមការតាមដាន ដោយនៅក្នុងនោះក៏មានក្រុមហ៊ុនធំៗនៅកម្ពុជាផងដែរ ។

ក្រុមហ៊ុនទាំង១៧ ដែលត្រូវបានក្រសួងបរិស្ថានដាក់នៅក្នុងការត្រួតពិនិត្យនោះ គឺមានទាំងក្រុមហ៊ុនលោក សុខ គង់ អារហ័ណ នីរហ័ណ និង ក្រុមហ៊ុនម៉ុងឫទ្ធីហ្គ្រោប។

ដីសម្បទានរបស់ក្រុមហ៊ុន សុខគង់ គឺមានទីតាំងស្ថិតនៅក្នុងឧទ្យានជាតិព្រះសុរាម្រិតកុសមៈ នៅខេត្តកំពង់ស្ពឺ ដោយឡែកក្រុមហ៊ុន ម៉ុងឫទ្ធីហ្គ្រោប គឺមានទីតាំងស្ថិតនៅសង្កាត់ជើងគោ ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ ។

លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា មកដល់ពេលនេះ ក្រសួងបានដកហូតដីសម្បទានសេដ្ឋកិច្ច ចំនួន ២៣ ក្រុមហ៊ុន ដោយមានបួនក្រុមហ៊ុន គឺបានស្ម័គ្រចិត្តប្រគល់ជូនរដ្ឋាភិបាលវិញ ក្រៅពីនោះ គឺមានក្រុមហ៊ុនមួយចំនួន បានសំរួលផ្ទៃដីដាំដុះ ក្រៅពីនោះ គឺដាក់ឲ្យក្រោមការតាមដាន។

លោកបានបន្តទៀតថា ក្រុមហ៊ុនដែលស្ម័គ្រចិត្ត ប្រគល់មកវិញនោះ មានក្រុមហ៊ុនមួយ គឺមិនអាចធ្វើអ្វីកើតដោយក្រុមហ៊ុន បានអះអាងថា ដីនោះ គឺត្រូវបានប្រជាពលរដ្ឋទន្ទ្រានកាន់កាប់។

លោកបានបន្តទៀតថា ថ្មីៗនេះ ក្រសួងបានសំរេច កាត់ដីសម្បទាននៅក្នុងខេត្តព្រះវិហារ ចំនួន ៥០០០ ហ.ត និងនៅបុទុមសាគរខេត្តកោះកុង ៩០០០ហ.ត ឲ្យទៅប្រជាពលរដ្ឋ ៕

# បំណុលនៅតែជាហានិភ័យស

វិស័យហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានអះអាងអំពីការរីកចំរើននៅកម្ពុជា ជាបន្តបន្ទាប់ នៅក្នុងនាមជាប្រភពទុនដ៏សំខាន់ សម្រាប់ពលរដ្ឋយកប្រើប្រាស់ជាប្រយោជន៍នៅក្នុងការបង្កើត និងពង្រីកមុខរបរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលនេះគឺមានពលរដ្ឋជាច្រើន ដែលបានរងគ្រោះដោយសារ តែការវ័ណ្ឌកនឹងបំណុលរបស់ស្ថាប័នទាំងនេះ ។

លោក អ្នកស្រី នេប អាយុ ៥៨ ឆ្នាំ ដែលមានមុខរបរជា អ្នកទូលនំអន្សមចេក និងនំគមតាមដងផ្លូវនៅរាជធានី បានអះអាងថា លទ្ធផលដែលគាត់មកទូលនំលក់នៅពេលនេះ គឺដោយសារតែបំណុលនេះឯង ។

ស្តាប់តាមការពន្យល់របស់លោកស្រី បំណុលដែលលោកស្រី និងគ្រួសារជំពាក់នេះ គឺរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុនេះឯង ប៉ុន្តែលោកស្រី មិនបានដឹងថា នោះគឺជាស្ថាប័នមីក្រូហិរញ្ញ-វត្ថុមួយណានោះទេ ដោយលោកស្រីបានហៅថា លុយដែលគេឲ្យលោកស្រី និងគ្រួសារខ្ចីនោះ គឺជាលុយរដ្ឋ។

លោកស្រី នេប បានអះអាងថា "ខ្ញុំអត់ស្គាល់អត់ដឹងអីទេ គឺឃើញតែដល់ខែរដ្ឋឲ្យគេជិះម៉ូតូ ជូនពីរនាក់ជួនម្នាក់មកយកលុយរាល់តែខែ "។

លោកស្រីបានឲ្យដឹងថា លោកស្រីក៏មិនដឹងថា លោកស្រីជំពាក់រដ្ឋនោះប៉ុន្មានទេ ដោយសារតែកូន គេសុំស្នាមមេដៃ ដោយគេយកលុយទៅរកស៊ីជួញមាន់ ដោយមួយខែៗ គឺគេទុកលុយ ៦០ ម៉ឺនរៀល ទុកសងរដ្ឋ( ស្ថា-ប័នមីក្រូហិរញ្ញវត្ថុ )ប៉ុន្តែដោយក្រោយមករបរនេះវាខាតគេក៏ទៅធ្វើការនៅរោង ចក្រ ហើយក៏បណ្តាលឲ្យលោកស្រី ជួយ រកសងបំណុលរដ្ឋទាំងអស់គ្នាទៅ។

លោកស្រី ដែលមានលំនៅក្នុងស្រុកឈូក ខេត្តកំពត បានអះអាងថា នៅមុនពេលដែល លោកស្រីយកលក់នំនៅភ្នំពេញនេះ គឺលោកស្រីបានលក់ដីស្រែមួយហើយ ដើម្បីទុកសងគេ ពីព្រោះពឹងលើប្រាក់ខែកូនស្រីធ្វើនៅរោងចក្រនៅភ្នំពេញ បានលុយផ្ញើមកផ្ទះនោះ គឺ២០ទៅ៣០ម៉ឺនរៀលមិនគ្រប់។ ដោយខ្លាចលក់ដីស្រែបន្តទៀត អត់មានដីធ្វើស្រែចិញ្ចឹមគ្រួសារលោកស្រីក៏បានមកភ្នំពេញ ស្នាក់នៅជាមួយកូនវេចនំដើរលក់ដូចរាល់ថ្ងៃ ។

នេះគឺជាប្រសាសន៍ របស់កូនបំណុល ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយរូប ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ លោក កៅ ពឿន ប្រធានសមាគមមន្ត្រីរាជការ ឯករាជ្យកម្ពុជា បានមានប្រសាសន៍ថា អ្នកដែលមានស្ថានភាពដូចជាលោកស្រី នេប គឺមានច្រើន ហើយក្រៅពីនោះក៏មានអ្នកដែលមានស្ថានភាពអាក្រក់ ជាងលោកស្រីថែមទៀតពោលគឺអស់ដីអស់ធ្លីដោយសារតបំណុលរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារនេះតែម្តង ។



រូបថត: លីហៀង

លោកបានមានប្រសាសន៍បញ្ជាក់ថា "អ្នកដែលរស់នៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ គឺមានច្រើន រហូតដល់អ្នកខ្លះរត់ចោលស្រុក ហើយខ្លះឲ្យកូនឈប់រៀន ជួយរកស៊ី រកការងារធ្វើដោយសារតែបំណុលនេះ"។

លោកបានបន្តទៀតថា មកដល់ពេលនេះ បើមានការអង្កេតឲ្យច្បាស់លាស់ត្រឹមត្រូវ ភាគរយនៃពលរដ្ឋចំ-ណាកស្រុកទៅរកការងារធ្វើ នៅប្រទេសជិតខាង ជាពិសេសគឺថៃ គឺដោយសារតែបំណុលនេះ គឺប្រាកដជាមានច្រើន។

លោកបានបន្តទៀតថា ជុំវិញបញ្ហាបំណុលនេះដើម្បីឲ្យមានប្រសិទ្ធិភាព ហើយអាចឲ្យស្ថាប័ន មីក្រូហិរញ្ញវត្ថុនេះក្លាយជាប្រភពទុន សម្រាប់ជួយដល់ប្រជាពលរដ្ឋពិតប្រាកដ គឺទាម-ទារឲ្យមានការអប់រំ និង ពន្យល់ប្រជា-ពលរដ្ឋឲ្យបានច្បាស់លាស់ មុនពេលដែលស្ថាប័នមីក្រូ ហិរញ្ញវត្ថុនីមួយៗ សំរេចចិត្តទម្លាក់លុយទៅពួកគាត់ ។

ជុំវិញបញ្ហាបំណុលនេះ មន្ត្រីឥណទានមួយរូប ដែលមានភារៈកិច្ចទទួលបន្ទុកកិច្ចការឥណទាននៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានឲ្យដឹងថា នៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្តសញ្ញាណថា ជាការពិតមុនពេលដែល សំរេចចិត្តផ្តល់ឥណ-ទាន( លុយ )ឲ្យទៅពលរដ្ឋខ្ចី គឺស្ថាប័នមីក្រូហិរញ្ញវត្ថុនីមួយៗទាមទារសិក្សាលំអិតច្រើន តាំងពីប្រភពប្រាក់ចំណូលលំហូរសាច់ប្រាក់ នៅក្នុងគ្រួសារលទ្ធ-ភាពនៃការសង ពោលគឺផ្តល់ប្រឹក្សាដល់ពួកគាត់អំពីហានិភ័យ និងជួយពន្យល់អំពីឱកាស និង បញ្ហាប្រឈមផ្សេងៗនៃបំណុលនេះ ហើយក្រោយពេលផ្តល់ គឺត្រូវបន្តតាមដានថា បំ-ណុលដែលគាត់ទទួលនេះ ត្រូវបានយកទៅប្រើប្រាស់ចំគោលដៅ ដែលគាត់ខ្ចីឬអត់ជាដើម ប៉ុន្តែជាតុពិតមកដល់ពេលនេះ គឺសឹងតែមិនមានអនុវត្តចំណុចទាំងនេះឡើយ ដោយសារតែការប្រកួតប្រជែង ។

លោកបានបញ្ជាក់ថា "បញ្ហានេះគឺបណ្តាលមកពី ការប្រកួតប្រជែង ហើយបើរវល់តែដើរ តាមលក្ខខណ្ឌច្រើនពេក យើងបាត់អតិថិជនគឺយើងក៏យ៉ាប់ដែរ "។

លោកបានបញ្ជាក់ទៀតថា"អតិថិជនតែមួយ មិនមែនមានតែខ្ញុំម្នាក់ៗទេដែលទៅទាក់ទងគាត់ គឺមានមន្ត្រីឥណទានជាច្រើន ដែលទៅទាក់ទងគាត់ ដូច្នេះតែគាត់យកស្ថាប័នគេយើងអត់ គឺច្បាស់ជាត្រូវមាត់មេហើយ "។

លោកបានបន្តទៀតថា នៅក្នុងនាមជាមន្ត្រីឥណទាន គឺរងសម្ពាធពីការងាររហូត ដោយសារតែម្នាក់ៗគឺស្ថាប័នដាក់កំណត់មកតែម្តង គឺដូចខ្ញុំចឹង គឺមួយខែត្រូវទំលាក់ប្រាក់កម្ចីទៅដល់អតិថិជន ឲ្យបាន១ម៉ឺនដុល្លារ បើរយៈពេលបីខែ ការងារអត់ទៅមុខការបញ្ចេញឥណទាន អត់បានតាមផែនការ គឺចូលទៅក្នុងបញ្ជីខ្មៅរបស់ស្ថាប័នហើយត្រូវមេស្តីឲ្យថែមទៀត។

# ាប់ពលរដ្ឋដែលខ្វះការយល់ដឹង

ដោយសារតែបញ្ហាទាំងនេះ ដូច្នេះ ហើយបានជា នៅពេលដែលចុះទៅទំនាក់ទំនងអតិថិជនម្តងៗ គឺថារកអតិថិជន ដែលគាត់ត្រូវការលុយបន្ទាប់មក គឺសិក្សាអំពីលទ្ធភាពសងរបស់គាត់ ហើយចុងក្រោយ គឺទ្រព្យបញ្ចាំ។

លោកបានបញ្ជាក់ថា "ជាគោលការណ៍របស់មន្ត្រីឥណទាន គឺធ្វើម៉េចកុំឲ្យបាត់ប្រាក់ដើម"។

ជុំវិញបញ្ហាដែល មន្ត្រីឥណទាននេះបានលើកឡើង លោក ប៊ុន មុនី ប្រធានសមាគមមីក្រូហិរញ្ញវត្ថុ កម្ពុជា បានមានប្រសាសន៍ថា សម្រាប់រឿងនេះ គឺដាច់ខាតមិនមែនជាបញ្ហាដែលកើតមានឡើង នៅក្នុងចំណោមបណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវឡើយ ជាពិសេសគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំៗ១០ នៅកម្ពុជា ។

លោកបានមានប្រសាសន៍ មុនពេលចុះទៅប្រតិបត្តិការ ឥណទាន មន្ត្រីឥណទានទាំងអស់ គឺត្រូវតែទទួលការបណ្តុះបណ្តាល ជំនាញ ក្រមសីលធម៌ និង អំពីគោលការណ៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

លោកបានបញ្ជាក់ថា "គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺត្រូវបានបង្កើតឡើងក្រោមគោលការណ៍ គឺដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ ផ្តល់ប្រភពទុនសម្រាប់ប្រជាពលរដ្ឋ បង្កើតមុខរបរបង្កើនចំណូល"។

លោក កៅ ពឿន បានឲ្យដឹងថា ដើម្បីបញ្ចៀសកុំឲ្យពលរដ្ឋ ក្លាយជាជនរងគ្រោះ ដោយសារតែបំណុល ទោះជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារ ឬ អ្នកចងការប្រាក់ មានតែការអប់រំនឹងពង្រឹង ក្រមសីលធម៌វិជ្ជាជីវៈប៉ុណ្ណោះ ដែលអាចជួយកាត់បន្ថយនូវហានិភ័យ នូវការបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេ ។

កាលពីពេលថ្មីៗ កន្លងទៅនេះ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏ធ្លាប់បានលើកឡើង អំពីកង្វល់ជុំវិញផលប៉ះពាល់មកលើប្រជាពលរដ្ឋ ជុំវិញបញ្ហាបំណុលនៅស្ថាប័ន មីក្រូហិរញ្ញវត្ថុនេះផងដែរ ។

លោកបាន មានប្រសាសន៍ថា ពលរដ្ឋកម្ពុជានៅទូទាំងប្រទេសបានជំពាក់បំណុល ស្ថាប័នមីក្រូហិរញ្ញវត្ថុ រហូតដល់ទៅ ៣.៥០០លានដុល្លារ ដូច្នេះ រដ្ឋាភិបាលអាចនឹងត្រូវដឹកនាំធ្វើការសិក្សាអំពីបញ្ហានេះ។

តាមប្រសាសន៍របស់លោក ស ខេង ក្រសួងមហាផ្ទៃ អាចជាស្ថាប័នដែលទទួលខុសត្រូវ ចំពោះបណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលគ្មានច្បាប់ត្រឹមត្រូវ ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ធនាគារជាតិជាអ្នកទទួលខុសត្រូវទាក់ទង ទៅនឹងមីក្រូហិរញ្ញវត្ថុយកការខ្ពស់។

ទាក់ទិននឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា កាលពីពេលថ្មីៗនេះ ក៏បានចេញផ្សាយនូវ សេចក្តីថ្លែងការណ៍រួម ដោយបានធ្វើការថ្កោលទោសចំពោះ សកម្មភាពរបស់មនុស្សមួយចំនួន ដែលបានបង្ហាញខ្លួនជាអង្គការមិនមែនរដ្ឋាភិបាល ជាសមាគមសប្បុរសធម៌ ឬជាសប្បុរសជនបានធ្វើសកម្មភាព ឱ្យខ្ចីប្រាក់តាមជនបទ និងទីប្រជុំជន ហើយចាត់ខ្លួនឯង ជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុយកអត្រាប្រាក់ខ្ពស់។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា បានប្រកាសថា សកម្មភាពឱ្យខ្ចីប្រាក់ ដោយពុំគ្រាន់ តែគ្មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងការយកការប្រាក់ខ្ពស់មានខុសបច្ចេកទេស គឺជាការកេងប្រវ័ញ្ច ហើយក៏បានប្រកាសថ្កោលទោស ចំពោះទង្វើខុសច្បាប់ទាំងនេះ ។

កាលពីដើមខែ មីនា ឆ្នាំ២០១៥ នេះ ធនាគារជាតិ នៃកម្ពុជាបានចាប់ផ្តើមធ្វើយុទ្ធនាការ ផ្សព្វផ្សាយអប់រំអំពីសេវាកម្មឥណទាន នៅក្នុងគោលបំណង ដើម្បីជួយការពារប្រជាពលរដ្ឋឲ្យចៀសវាង ការកេងប្រវ័ញ្ចពីសំណាក់ ក្រុមអ្នកដែលប្រកបរបរផ្តល់ឥណទាន ដែលភាសារសាមញ្ញហៅថាចងការប្រាក់។

លោក ជា ចាន់តូ បានមានប្រសាសន៍ កាលពីថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០១៥ នៅក្នុងសិក្ខាសាលាមួយនៅខេត្តកំពង់ចាមថា រាល់ការផ្តល់ឥណទាន ឬក៏ប្រាក់កម្ចី គឺ ត្រូវតែអនុវត្តជាមួយនឹងយន្តការទីផ្សារ និង គោលនយោបាយ របស់រាជរដ្ឋាភិបាល ហើយបានហៅក្រុមអ្នករកស៊ីចងការប្រាក់ ដែលក្រៅច្បាប់ដែលយកការប្រាក់ខ្ពស់ថា ជាអ្នកកេងប្រវ័ញ្ច និងបានប្រកាសថ្កោលទោសចំពោះស្ថាប័ន អ្នកចងការប្រាក់ក្រៅប្រព័ន្ធទាំងនោះ។

លោកក៏បានប្រកាស ឲ្យបណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលស្របច្បាប់ បន្តធ្វើការបន្ធូបន្ថយអត្រាការប្រាក់បន្តទៀតដល់ប្រជាពលរដ្ឋ សំដៅកាន់បន្ថយហិនិភ័យអាជីកម្មដែលបណ្តាលមកពីវិបត្តិនៃបំណុល ហើយក៏បានជំរុញឲ្យ ស្ថាប័នហិរញ្ញវត្ថុទាំងអស់ អនុវត្តនូវក្រម ស្តីពីការប្រតិបត្តិសេវាធនាគារ ដែលទើបតែប្រកាសដាក់ឲ្យប្រើប្រាស់កាលពីខែ កុម្ភៈ និង គោលការណ៍កិច្ចការពារ អតិថិជន សំដៅការពារផលប្រយោជន៍ និង សិទ្ធិរបស់អតិថិជន៕

**ដោយអរិយបុត្រ**

## អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា៖ ធនាគារជាតិបានទទួលការស្នើសុំចុះបញ្ជី ពីស្ថាប័នមីក្រូហិរញ្ញវត្ថុជាង១០០

លោក ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា បន្ទាប់ពីលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានព្រមានធនាគារជាតិនៃកម្ពុជា បានទទួលសំណើរចុះបញ្ជីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាង១០០ ។

លោក ជា ចាន់តូ បានមានប្រសាសន៍ក្នុងពេលចូលជាអធិបតីក្នុងពិធីចុះហត្ថលេខាលើក្រមស្តីពី "ការប្រតិបត្តិសេវាធនាគារ" ថាចំពោះមីក្រូហិរញ្ញវត្ថុ ដែលបានយកការប្រាក់ខ្ពស់ពេកនឹងមានវិធានការតាមផ្លូវច្បាប់ ហើយមកដល់ពេលនេះមីក្រូហិរញ្ញវត្ថុ ដែលមិនទាន់បានចុះបញ្ជីនោះ គឺបានមកចុះបញ្ជីបានជាង ១០០ មីក្រូហិរញ្ញវត្ថុហើយ។

លោកបានបន្តទៀតថា មកដល់ពេលនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីហើយ សព្វថ្ងៃប្រមាណ ១៣៥ គ្រឹះស្ថាន ។

សម្រាប់បញ្ហាអត្រាការប្រាក់វិញ លោក ប៊ុន មុនី ប្រធានសមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាបានមានប្រសាសន៍ថា មកដល់ពេលនេះ កំរិតនៃអត្រាការប្រាក់របស់គ្រឹះស្ថានមីកូហិរញ្ញវត្ថុ គឺនៅត្រឹមកំរិតពី១,២ ទៅ ២ ភាគរយក្នុង១ខែប៉ុណ្ណោះជាមធ្យម ។

## នាយករដ្ឋមន្ត្រី៖ រដ្ឋមិនមែនជាម្ចាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា រដ្ឋមិនមែនជាម្ចាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍នាព្រឹកថ្ងៃទី១០ កុម្ភៈ នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ ក្នុងពិធីចែកសញ្ញាបត្រនិស្សិតកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ថា កន្លងទៅ មានបញ្ហាការនិយាយថា មីក្រូហិរញ្ញវត្ថុជារបស់រដ្ឋ ហើយរដ្ឋបានរឹបអូសដីធ្លី ផ្ទះសម្បែង របស់ពលរដ្ឋ តាមរយៈមីក្រូហិរញ្ញវត្ថុនេះ ប៉ុន្តែជាតុពិត គឺមីក្រូហិរញ្ញវត្ថុ។

សម្តេចបានបញ្ជាក់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់មិនមែនជារបស់រដ្ឋទេ គឺជារបស់ឯកជនហើយអ្វីដែលជារបស់រដ្ឋគឺធនាគារជាតិ។

សម្តេចតេជោបានព្រមានគ្រឹះស្ថានដែលមិនស្របច្បាប់ និង ក៏បានអំពាវនាវបណ្តា ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា ឲ្យមានការប្រយ័ត្នប្រយែង និងធ្វើការវាយតម្លៃក្រុមគ្រួសារកសិករមុនពេលឲ្យខ្ចី ។

# សារលិខិតសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សម្រាប់ទិវាសន្តិភាពពិភពលោក
## ០១ មករា ២០១៥

### មនុស្សលែងទៅជាទាសករទៀតហើយ គឺជាបងប្អូនវិញ


រូបថតៈ សម្បត្តិ

១. យើងទទួលឆ្នាំអន្តរជាតិ ទុកជាព្រះអំណោយទាន របស់ព្រះបិតា ប្រកបដោយ ព្រះហឫទ័យប្រណីសន្តោសមកយើង។ នៅដើមឆ្នាំនោះ ខ្ញុំសូមជូនពរ សព្វសាធុការជ័យមង្គល ចំពោះមនុស្សទាំងអស់ ទាំងបុរសទាំងស្ត្រីគ្រប់ៗរូប ក្នុងពិភពលោក។ ខ្ញុំសូមជូនពរឲ្យប្រទេសជាតិនានាបានសេចក្តីសុខសាន្ត និង បានចម្រុងចម្រើនឡើង។ ខ្ញុំសូមជូន និងថ្វាយព្រះពរចំពោះប្រមុខរដ្ឋ និង នាយករដ្ឋាភិបាលនានា ព្រមទាំងសូមជូន និង ថ្វាយព្រះពរចំពោះអស់លោក ដែល ទទួលខុសត្រូវក្នុងការណែនាំសាសនាទាំងឡាយ។ ខ្ញុំទទូចអង្វរព្រះបិតាសូមព្រះអង្គប្រោសឲ្យមនុស្សបញ្ឈប់ធ្វើសង្គ្រាម បញ្ឈប់ទាស់ទែងគ្នា មិនឲ្យមានទុក្ខបណ្តាលមកពីមនុស្សបានបង្កើតមក ឬបណ្តាលមកពីជំងឺរោគាព្យាធិ ទាំងចាស់ទាំងថ្មីរាតត្បាតក្នុងពិភពលោក ឬ បណ្តាលមកពីគ្រោះកាចធម្មជាតិទៀតផង។ ខ្ញុំសូមអង្វរព្រះបិតាយ៉ាងពិសេសសូមព្រះអង្គប្រោសប្រទាន ឲ្យយើងទាំងអស់គ្នាអាចឈ្នះការល្បួង ចង់រស់នៅតាមបែបមិនសមគួរ នឹងឋានៈរបស់ខ្លួនជាមនុស្ស។ ធ្វើដូច្នេះទើបយើងនឹងអាចបំពេញ តាមឧបនិស្ស័យរួម គឺ រួមសហការជាមួយព្រះបិតា និង ជាមួយមនុស្សទាំងឡាយ ដែលមានឆន្ទៈល្អពង្រីកនិងពង្រឹងការស្រុះស្រួលគ្នា និង ពង្រឹងសន្តិភាព ក្នុងពិភពលោកទាំងមូល។

នៅថ្ងៃទី ០១ មករា ឆ្នាំ ២០១៤ ខ្ញុំបានសង្កេតឃើញថា "មនុស្សយើងមានបំណងចង់បានជីវិត យ៉ាងពេញលេញ យើងស្រេកឃ្លានចង់រួបរួមគ្នាជាបងប្អូន ជាបំណងដែលឃាត់ពុំបាន។ បំណងនោះជំរុញមនុស្សយើងឲ្យចង់រួបរួមជាមួយអ្នកដទៃ គឺ យើងមិនរាប់អ្នកដទៃទុកជាខ្មាំង ឬ ទុកជាអ្នកប្រណាំងប្រជែងនឹងខ្លួនទេ តែផ្ទុយទៅវិញ យើងរាប់គេទុកជាបងប្អូនដែលយើងត្រូវទទួល និងត្រូវស្រ-

ឡាញ់រាប់អានដោយចិត្តស្មោះ" ។ តាមធម្មជាតិមនុស្សយើងអាចចម្រើនឡើងបាន លុះត្រាតែខ្លួនមានទំនាក់ទំនងជាមួយអ្នកដ៏ទៃ ជាទំនាក់ទំនងហូរមកពីយុត្តិធម៌ និង សេចក្តីស្រឡាញ់។ ហេតុនេះត្រូវតែទទួលស្គាល់ និង គោរពកិត្តិយសដ៏ថ្លៃថ្នូរ របស់អ្នកដទៃ ត្រូវទទួលស្គាល់ និងគោរពសេរីភាព និងស្វ័យភាពរបស់គេជាកំហិត។ ប៉ុន្តែគួរឲ្យស្តាយណាស់ មនុស្សតែងតែជិះជាន់មនុស្សដូចគ្នា។ ការជិះជាន់នេះ បំផ្លាញការរួមរស់ជាមួយគ្នា និង ខុសស្រឡះ នឹងឧបនិស្ស័យរបស់មនុស្ស ដែលមានបំណងចង់មានទំនាក់ទំនងទៅវិញទៅមក ប្រកបដោយការគោរពដោយយុត្តិធម៌ និង ដោយសេចក្តីស្រឡាញ់។

សភាពការណ៍បែបនេះ អាក្រក់ណាស់ បណ្តាលឲ្យបំបាត់កិត្តិយស និង សិទ្ធិជាគ្រឹះរបស់អ្នកដទៃ ហើយក៏ណ្តាលឲ្យបំផ្លាញសេរីភាព និង សេចក្តីថ្លៃថ្នូររបស់គេទៀតផង។ ខ្ញុំមានបំណងចង់រិះគិតយ៉ាងខ្លី អំពីរបៀបផ្សេងៗ នៃសភាពការណ៍ដ៏អាក្រក់នេះដើម្បីឲ្យ "យើងលែងរាប់អ្នកដទៃទុកជាទាសករទៀត តែឲ្យរាប់គេទុកជាបងប្អូនវិញ"។ ខ្ញុំនឹងរិះគិតបែបនេះ ដោយលើកយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកធ្វើជាពន្លឺមកបំភ្លឺ។

(តទៅលេខក្រោយ......)

# លោកអភិបាលសំណេះសំណាលនិងលើកទឹកចិត្តចាស់ជរា

លោកអភិបាល អូលីវីយេ ជ្មឺត ហស្លេរ នៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ រួមនិងលោក តឹក តុងលីម ជាអភិបាល នៃគណៈអភិបាលស្រុក ត្រាំកក់បានរៀបចំកម្មវិធីសំណេះសំណាល ជាមួយមនុស្សចាស់ៗ ចំនួន១០០នាក់ ដែលមកពីឃុំចំនួន៣ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៦ មករាកន្លងទៅ នៅភូមិព្រៃរំដេង ឃុំអង្គតាសោម ស្រុកត្រាំកក់ខេត្តតាកែវ។

ក្នុងពិធីនោះលោកអភិបាល អូលីវីយេ បានសំណូមពរ ដល់លោកតាលោកយាយ ឲ្យជួយផ្តល់សក្ខីភាពអំពីការលំបាកនៃជីវិត ឲ្យកូនចៅជំនាន់ក្រោយ ដើម្បីឲ្យគេមានការតស៊ូនៅក្នុងជីវិតរបស់គេថែមទៀត ព្រមទាំងសូមឲ្យចាស់ព្រឹទ្ធាចារ្យទាំងអស់បញ្ជូនបន្តនូវ សីលធម៌ គុណធម៌ ព្រហ្មវិហារធម៌ ឲ្យកូនចៅដើរនៅក្នុងផ្លូវត្រឹមត្រូវ និងសូមពួកគាត់បន្តអប់រំណែនាំកូនចៅ ឲ្យចេះការពារថែរក្សាវប្បធម៌ប្រពៃណីជាតិ ដើម្បីឲ្យក្មេងៗអាចកសាងអនាគត លើគ្រឹះដ៏រឹងមាំនៃកេរ្តិ៍ដំណែលពីដូនតា។

លោក តឹក តុងលីម បានថ្លែងអំណរគុណ និងធ្វើការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះ សកម្មភាពមេត្តាករុណា របស់ព្រះសហគមន៍កាតូលិក ដែលបានជួយដល់ប្រជាពលរដ្ឋស្រុកត្រាំកក់ តាមរយៈប្រព័ន្ធអប់រំកម្មវិធីសង្គហៈផ្សេងៗ។ លោកក៏បានបន្តថា លោកសូមធ្វើការប្តេជ្ញាចិត្តគាំទ្រ នូវរាល់សកម្មភាពប្រកបដោយគុណធម៌របស់ព្រះសហគមន៍កាតូលិកនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវនេះ។


លោកអភិបាលថតរូបអនុស្សាវរីយ៍ជាមួយចាស់ៗ។ រូបថតៈ សុធីរិទ្ធិ

ក្រោយពីកម្មវិធីសំណេះសំណាលនេះលោកអភិបាលនិងលោក តឹក តុងលីម បានចែកជូនអំណោយជាគ្រឿងឧបភោគបរិភោគ ជូនដល់ចាស់ព្រឹទ្ធាចារ្យទាំង១០០នាក់ ដែលមានមកពីឃុំអង្គតាសោម ឃុំតាភេម និង ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។ ក្នុងនោះដែរ មណ្ឌលសកម្មភាពតាកែវក៏បានរៀបចំ ពិធីពិសាអាហារសាមគ្គីរួមគ្នាផងដែរ៕

**ដោយដាលីស**

# ព្រះសគមន៍ផ្នុកទ្រូនឹងប្ដូរជីវិតថ្មីលើដីគោក

បើយើងធ្វីដំណើរ ចាកចេញពីទីរួមស្រុកបរិបូរណ៍ ឆ្ពោះទៅមាត់បឹងទន្លេសាប ប្រមាណជា២០នាទី តាមផ្លូវលំក្នុងរដូវប្រាំង យើងនឹងទៅដល់ភូមិបណ្ដែតទឹកមួយ មានឈ្មោះថាភូមិផ្នុកទ្រូ ស្ថិតក្នុងឃុំផ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ ពេលទៅដល់ទីនោះ អ្នកនឹងពិបាកទ្រាំ ព្រោះតែក្លិនស្អុយឆ្អាប ដែលចេញពីទឹកនៅមាត់កំពង់ទូកនេះ។ ដើម្បីទៅក្នុងភូមិ យើងត្រូវជិះទូកដោយឆ្លងកាត់លើទឹក ដែលមានក្លិនស្អុយឆ្អាបនេះ ។

ការធ្វើដំណើរមិនយូរប៉ុន្មាន ចូលដល់ក្នុងភូមិ យើងនឹងបានឃើញពីរបៀបរស់របស់ប្រជាជន ដែលមានផ្ទះនៅលើផ្ទៃទឹក។ ផ្ទះរបស់គេមានតូចមានធំ មានហាងលក់ទូរស័ព្ទដៃ មានកន្លែងលក់កាហ្វេ។ល។ មិនយូរប៉ុន្មាន យើងនឹងបានទៅដល់ផ្ទះធំល្មមមួយ បណ្ដែតនៅទឹកយ៉ាងសង្ហា និង មានឈើឆ្កាងមួយនៅចំពីលើ។ នោះគឺព្រះវិហារ សន្តអន់តូនី នៃព្រះសហគមន៍កាតូលិក ផ្នុកទ្រូក្នុងភូមិភាគបាត់ដំបង។

មកដល់កន្លែងនេះ យើងលែងធុំក្លិនស្អុយក្លិនឆ្អាបទៀតហើយ ព្រោះព្រះវិហារនេះ បានស្ថិតនៅឆ្ងាយល្មមពីទីប្រជុំជន ដែលមានមនុស្សរស់នៅច្រើន។ នៅពេលល្ងាច ពន្លឺព្រះអាទិត្យពណ៌មាសចាំង ឆ្លុះមកលើផ្ទៃទឹក ហាក់ជាក្រាលព្រំមាស។ នៅលើអាកាសមានសត្វរំពេរ និងបក្សាបក្សីជាច្រើន ហើរឆ្វែលឆ្វាត់កាន់តែបង្កើនភាពស្រស់ស្អាត នៃទីសក្ការបូជានេះមួយកំរិតទៀត ដែលជាទីគួរឲ្យគយគន់ពន់ពេក។ ប៉ុន្តែ ភាពរមនាទីនេះនៅមិនបានយូរប៉ុន្មាន ទៀតទេព្រះវិហារមួយនេះនឹងប្ដូរទី តាំងទៅលើដីគោកវិញ ដែលនៅមិនឆ្ងាយពីភូមិបណ្ដែតទឹកនេះទេ។

តាមប្រសាសន៍ដូនជី ម៉ារីយ៉ាយ៉ឺង ជាអ្នកសម្របសម្រួស ក្នុងព្រះសហគមន៍បានឲ្យដឹងថា៖ ព្រះវិហារនេះនឹងត្រូវប្ដូរទីតាំង ទៅសង់នៅលើដីគោកវិញ នៅតាមបណ្ដោយផ្លូវពីទីរួមស្រុកបរិបូរណ៍ ទៅផ្នុកទ្រូដែរ។ ដូនជីរូបនេះបន្តថា អាគារព្រះវិហារនៅលើទឹកនេះ យើងជួសជុលច្រើនលើកច្រើនសារ ហើយការជួសជុលទៀតក៏ចំណាយថវិការ ច្រើនណាស់ដែរ។ ហេតុនេះ ព្រះសហគមន៍សម្រេចចិត្តស្វែងរកដីមួយកន្លែង ដើម្បីសាងសង់នៅលើដីគោកវិញ។

អមជាមួយអគារព្រះវិហារ ថ្មីនេះ ព្រះសហគមន៍កាតូលិក ក៏នឹងសាងសង់ផ្ទះជូនគ្រីស្តបរិស័ទ ចំនួន១៥ គ្រួសារ ឲ្យរស់នៅជុំវិញព្រះវិហារក្នុងបរិវេណដីរបស់ព្រះសហគមន៍។

តាមការរៀបរាប់របស់លោកយ៉ាំងភុក សមាជិកគណកម្មការព្រះសហគមន៍មានប្រសាសន៍ថា ក្នុងឆ្នាំ១៩៩៧ គ្រីស្តបរិស័ទក្នុងភូមិនេះ មានចំនួនច្រើន គឺប្រមាណជា ១០០ គ្រួសារ។ តែក្រោយមក ចេះតែចុះជាលំដាប់ ព្រោះគ្រីស្តបរិស័ទជាច្រើន បានចំណាកស្រុក ដើម្បីស្វែងរកទីកន្លែងសម្រាប់ចិញ្ចឹមជីវិត។ សព្វថ្ងៃ ព្រះសហគមន៍មានគ្រីស្តបរិស័ទប្រមាណជា២០គ្រួសារប៉ុណ្ណោះ។



ព្រះវិហារសន្តអន់តូនីផ្នុកទ្រូ។ រូបថតៈ លី សុវណ្ណា

លោក ភុក រៀបរាប់ថា៖ ការផ្លាស់ប្ដូរទីកន្លែងនេះ ទាំងព្រះសហគមន៍ និងគ្រីស្តបរិស័ទ ត្រូវសម្របក្នុងជីវភាពថ្មីលើដីគោក ព្រោះពួកគេធ្លាប់រស់នៅលើទូក ក្នុងភូមិផ្នុកទ្រូនេះ ខ្លះ ២៥ឆ្នាំ ខ្លះ៣០ឆ្នាំ គឺពួកគេរស់នៅតាំងពីកំណើតរបស់គេ។ ហេតុនេះ បញ្ហាប្រឈមនានា នឹងកើតឡើងគ្រប់ពេល។តែលោកថា៖"យើងត្រៀមខ្លួនរួចរាល់ហើយ"។ លោកនៅតែប្រកបរបរលើទូកដដែល ទំរាំអាចសម្របខ្លួននឹងជីវភាពលើដីគោកបាន។

ព្រះសហគមន៍កាតូលិក ផ្នុកទ្រូ បានកើតឡើងក្នុងអំឡុងឆ្នាំ១៩៩៧។ ព្រះសហគមន៍នេះ បានខិតខំរស់នៅយ៉ាងជិតស្និទ្ធជាមួយប្រជាជន តាមរយៈកិច្ចការសង្គហៈ ជួយអ្នកក្រីក្រ ចាស់ជរា កុមារ។ កិច្ចការផ្នែកសុខភាព មានជូនអ្នកជំងឺទៅមន្ទីពេទ្យ សួរសុខទុក្ខតាមផ្ទះ និងជួយព្យាបាលជំងឺសរសៃ។ ហើយក៏មានកម្មវិធីអប់រំចំណេះទូទៅ និងអប់រំជំនឿ ។

ដូនជីម៉ារីយ៉ា យ៉ឺង បានរៀបរាប់ថា ព្រះសហគមន៍ មានថ្នាក់អប់រំជំនឿដល់ កុមារជាកូនរបស់គ្រីស្តបរិស័ទ។ ការអប់រំគ្រួសារ ដើម្បីឲ្យមានជំនឿរឹងមាំ ជួយគេឲ្យចេះអនុវត្តតាមព្រះបន្ទូល តាមរយៈការរស់នៅ និង ពាក្យសំដី។ ជួយគេឲ្យ យល់ពីតម្លៃនៃគ្រួសារ ព្រោះគូស្រករជាច្រើន រៀបការក្នុងវ័យក្មេង គ្មានអត្តសញ្ញាអាពាហ៍ពិពាហ៍ទេ ហេតុនេះអំពើហិង្សាក៏មានច្រើនក្នុងគ្រួសារ ទាំងកាយវិការ និងពាក្រសំដី។ តាមរយៈកម្មវិធីអប់រំចំណេះដឹងទូទៅ ដូនជី ម៉ារីយ៉ា យ៉ឺងបន្តថា៖ យើងមានថ្នាក់មត្តេយ្យ និង បឋម ដើម្បីឲ្យកុមារអាចសម្របខ្លួនបាន មុនពេលពួកគេចូលរៀននៅសាលារដ្ឋ។ ជាមួយគ្នានេះ ព្រះសហគមន៍ ក៏មានថ្នាក់អក្ខរកម្មភាសាខ្មែរ និងបរទេសផងដែរ ។

ព្រះសហគមន៍កាតូលិក ផ្នុកទ្រូ ស្ថិតនៅ ក្រោមការទទួលខុសត្រូវរបស់លោក ង៉េត វិន័យ ជាបូជាចារ្យកាតូលិកជាតិកម្ពុជា៕ **ដោយលី សុវណ្ណា**

# សន្តីបេណាដែត



ឪពុកម្ដាយរបស់នាង បេណាដែត មានជីវភាពក្រីក្របំផុត។ ពួកគាត់រស់នៅទីក្រុងលួដ៍ នៅខាងត្បូងប្រទេសបារាំង។ ថ្ងៃមួយនៅឆ្នាំ១៨៥៤ ខណៈដែលនាង បេណាដែត កំពុងរើសឧស ស្រាប់តែមានស្ត្រីដ៏ស្រស់ស្អាតម្នាក់ មកឈរនៅពីខាងមុខនាងក្នុងរូងថ្មមួយ។ ស្ត្រីនោះស្លៀកពាក់ពណ៌ខៀវ និងស ហើយមានផ្កាកុលាបទ្រទើងរបស់គាត់ផង។ ស្ត្រីនោះញញឹមមកកាន់នាង បេណាដែត ទាំងសុំឲ្យនាងអធិដ្ឋានជាមួយគាត់។ ក្រោយមកស្ត្រីនោះបង្ហាញខ្លួនឲ្យនាង បេណាដែត បានឃើញចំនួន១៨ដងទៀត។ ស្ត្រីនោះសុំឲ្យនាងបេណាដែតប្រាប់មនុស្សទាំងឡាយថា ត្រូវតែប្រែចិត្តគំនិត និង អធិដ្ឋានជានិច្ច។ ថ្ងៃមួយស្ត្រីនោះមានប្រសាសន៍ទៅនាង បេណាដតថា៖ " ខ្ញុំសន្យាឲ្យកូនមានសុភមង្គល តែមិនមែនសុភមង្គលនៅក្នុងលោកនេះទេគឺនៅស្ថានបរមសុខវិញ"។

មហាជនជាច្រើនបានដើរតាមនាង បេណាដែត ទៅរូងថ្មនោះដើម្បីអធិដ្ឋានជាមួយនាង។ ប៉ុន្តែពួកគេមិនអាចមើលឃើញស្ត្រីនោះឡើយ។ ថ្ងៃមួយស្ត្រីនោះបានសុំឲ្យនាង បេណាដែត កាយដីហើយស្រាប់តែមានទឹកផុសឡើង។ មានមនុស្សជាច្រើនដែលផឹកទឹកនោះបានជាសះស្បើយពីជំងឺគ្រប់បែបយ៉ាង។ នៅពេលដែលនាង បេណាដែត សុំស្គាល់ឈ្មោះ ស្ត្រីនោះងើបមុខឡើង ទាំងពោលថា ៖ "ខ្ញុំជាស្ត្រីម្នាក់ដែលមិនជំពាក់បាបតាំងពីកំណើតគឺខ្ញុំនេះហើយជាព្រះនាងម៉ារី "។ បន្ទាប់មក ព្រះនាង ម៉ារី សុំឲ្យមានព្រះវិហារថ្មីមួយនៅជិតរូងថ្មនោះ។ ក្រោយមក នាង បេណាដែត ចូលបួស ហើយនាងរងទុក្ខលំបាកយ៉ាងខ្លាំងដោយសារជំងឺ។ នាងទទួលមរណភាពនៅអាយុ៣៦ឆ្នាំតែប៉ុណ្ណោះ៕

# ព្រះសហគមន៍តាហែន ផ្តល់ជូនទឹកដោះគោដល់គ្រួសារអ្នកផ្ទុកមេរោគអេដស៍ នៅឃុំរការ

ដើម្បីជួយសម្រាល បន្ទុកការចំណាយរបស់គ្រួសារ ដែលមានទារកក្នុងបន្ទុក និង ដែលកំពុងផ្ទុកមេរោគអេដស៍ នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង គណៈកម្មការសង្គហៈ នៃព្រះសហគមន៍តាហែន បានផ្តល់ជូនទឹកដោះគោ សម្រាប់ទារកពីអាយុ ១ខែ ឡើងទៅជាទៀតទាត់ ចាប់តាំងពីពាក់កណ្តាលខែមករាដើមឆ្នាំនេះ។

អ្នកស្រី ផាំ មិច ជាប្រធានគណៈកម្មការទទួលខុសត្រូវ នៃព្រះសហគមន៍តាហែន បានឲ្យដឹងថា គណៈកម្មការ ព្រះសហគមន៍តាហែន រួមជាមួយលោកអភិបាល និងលោកបូជាចារ្យទទួលខុស ត្រូវព្រះសហគមន៍បានសម្រេចជួយទឹកដោះគោ សម្រាប់ទារកដែល កំពុងបៅដោះម្តាយ ដើម្បីកុំឲ្យទារកឆ្លងមេរោគអេដស៍ ពីម្តាយតាមរយៈការបំបៅដោះនេះ ដោយឲ្យស្ត្រីជាម្តាយងាកមករក ការបំបៅកូនជាមួយទឹកដោះគោវិញ ។

អ្នកស្រីបន្តថា ក្នុងចំណោមបងប្អូនប្រជាពលរដ្ឋ ប្រមាណជិត៣០០ នាក់ នៅក្នុងឃុំរកា ដែលផ្ទុកមេរោគអេដស៍ មានស្ត្រីជាមេផ្ទះមួយចំនួនបាននិងកំពុងបំបៅដោះកូន ហើយក៏មានសមាជិកគ្រួសារមួយចំនួន ផ្ទុកមេរោគអេដស៍ទាំងគ្រួសារតែម្តងព្រមទាំងមានជីវភាពខ្វះខាតជាខ្លាំង ។

អ្នកស្រី ផាំ មិច បានបញ្ជាក់ថា ជាជំហានដំបូង គណៈកម្មការព្រះសហគមន៍តាហែន បានជួយជាទឹកដោះគោ សម្រាប់ទារក បានចំនួន ១៤ នាក់ ចាប់តាំងពីពាក់កណ្តាលខែមករា ឆ្នាំ២០១៥កន្លងមកនេះ ហើយក្នុងនោះ មានទារកអាយុចាប់ពី១ខែ ដល់៥ខែ មានចំនួន៦នាក់ និង ទារកមានអាយុ៥ខែ ដល់៨ខែ មានចំនួន៨នាក់ ហើយការផ្តល់ជូនទឹកដោះគោនេះ នឹងធ្វើរហូតដល់ទារកដល់វ័យឈប់បៅ។

អ្នកស្រីបានឲ្យដឹងទៀតថា ក្នុងពេលឆាប់ៗខាងមុខនេះ ព្រះសហគមន៍មានគម្រោងចែកជូន ជាអង្ករ និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត ដល់គ្រួសារដែល ផ្ទុកមេរោគអេដស៍នៅឃុំរកា ខេត្តបាត់ដំបងនេះ។

ការផ្ទុះរីករាលដាលឡើងវិញ នៃអ្នកផ្ទុកមេរោគអេដស៍ ជាទ្រង់ទ្រាយធំនៃអ្នកភូមិរការក្នុង ខេត្តបាត់ដំបង ត្រូវបានឲ្យដឹង កាលពីពាក់កណ្តាលខែធ្នូកន្លងទៅដែលមានអ្នកផ្ទុកចំនួនប្រមាណជាជិត ១០០០នាក់ កំពុងឆ្លងមេរោគអេដស៍ដោយសារគ្រូពេទ្យគ្មានអាជ្ញាបណ្ណ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលលោក ម៉ម ប៊ុនហេង បានមានប្រសាសន៍ កាលពីថ្ងៃទី ២៨ មករាកន្លងទៅថា ក្រសួងសុខាភិបាលនឹងលុបបំបាត់ សេវាសុខភាពក្រៅប្រព័ន្ធ ពោលគឺស្ថាបនដែលគ្មានអាជ្ញាបណ្ណត្រឹមត្រូវ នាពេលខាងមុខនេះ៕

**ដោយឡុង សម្ផស្ស**

# ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងបានត្រាស់ហៅបងប្អូនចំនួន៦៤នាក់ យ៉ាងឱឡារិកឲ្យត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក

លោកអភិបាលគីគេ ហ្វីការេដូជាអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានត្រាស់ហៅបេក្ខជនបេក្ខនារី ចំនួន ៦៤នាក់ យ៉ាងឱឡារិក ដែលមកពីព្រះសហគមន៍ នានាក្នុងភូមិភាគ បាត់ដំបង កាលពីថ្ងៃទី០១ ខែមីនាកន្លងទៅនៅព្រះវិហារព្រះជាម្ចាស់ លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខ ស្ថិតនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានអ្នកចូលរួមប្រមាណជាង ៥០០ នាក់។

លោកអភិបាល គីគេ បានមានប្រសាសន៍ថា នៅថ្ងៃនេះព្រះសហគមន៍កាតូលិកយើង មានអំណរសប្បាយ ដោយសារមាន បងប្អូនចំនួន ៦៤ នាក់ទទួលពិធីត្រាស់ហៅ យ៉ាងឱឡារិក ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លងខាងមុខនេះ។ លោកបន្តថា ពេលនេះ ជាបទពិសោធន៍ពិសេសមួយដែលព្រះជាម្ចាស់ត្រាស់ហៅបងប្អូន ៦៤នាក់ ឲ្យដើរតាមព្រះយេស៊ូ ហើយក៏ជាពេលដែលព្រះសហគមន៍មានអំណរក្នុងការទទួលបងប្អូនដូចបុត្រធីតារបស់ព្រះជាម្ចាស់ឲ្យចូលរួមក្នុងព្រះសហគមន៍ របស់ព្រះអង្គដែរ។ ក្នុងជីវិតរបស់បងប្អូនម្នាក់ៗ តែងតែជួបនូវការលំបាក និងជួបឧបសគ្គនានាប៉ុន្តែសូមឲ្យបងប្អូនភ្ជាប់ជីវិតរបស់ខ្លួនជាមួយព្រះយេស៊ូ។

ដោយសារពេលនេះ ព្រះសហគមន៍កាតូលិកស្ថិត នៅក្នុងរដូវត្រណម លោកអភិបាល ក៏បានមានប្រសាសន៍ទៅកាន់បងប្អូនថ្មីៗទាំងនោះ ឲ្យប្រែចិត្តគំនិត ដើម្បីយើងចូលរួមជាមួយព្រះយេស៊ូ ដែលបានសោយទីវង្គត និង មានព្រះជន្មរស់ឡើងវិញនាឱកាសថ្ងៃបុណ្យចម្លងនេះ។

ក្នុងឱកាសនេះ លោកអភិបាល ក៏បានរំឭកដល់បងប្អូនជាគ្រីស្តបរិស័ទដែលបានចូលរួម ក្នុងពិធីត្រាស់ហៅនាពេលនេះ ឲ្យយកចិត្តទុកដាក់ជួយគាំទ្រដល់អស់បងប្អូនដែល ទើបតែបានទទួលពិធីត្រាស់ហៅនាពេលនេះ ដោយជួយអធិដ្ឋាន សម្រាប់ពួកគេ ដើម្បីឲ្យគេ មានជំនឿកាន់តែមាំមួនឡើងៗព្រមទាំងជួយ ឲ្យបងប្អូនទាំងនោះឲ្យធ្វើដំណើរទៅមុខទៀត ដោយផ្ញើជីវិតលើព្រះអង្គ និង ជំនះនូវរាល់



បេក្ខជនទទួលពិធីត្រាស់ហៅយ៉ាងឱឡារិកពីលោកអភិបាលគីគេ។

ការល្បួងទាំងឡាយ។

មានចំណាប់អារម្មណ៍នាពេលនោះ កញ្ញាម៉ារីយ៉ាយ៉ុងសុភ័ក្រ្ត អាយុ១៧ ឆ្នាំ បេក្ខនារីមកពីព្រះសហគមន៍កាតូលិកតំបន់កំពង់ធំ បានឲ្យដឹងថានាងមានអំណរសប្បាយ យ៉ាងក្រៃលែង ដែលបានទទួលពិធីត្រាស់ហៅយ៉ាងឱឡារិកឬជំហានទី២នាថ្ងៃនេះ ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក។ យុវតីរូបនេះបន្តថា៖ "ក្នុងជីវិតរបស់ខ្ញុំមានការអស្ចារ្យជាច្រើន ដែលជាសញ្ញាថា ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំ។ ព្រះជាម្ចាស់ផ្តល់នូវព្រះអំណោយទានគ្រប់បែបយ៉ាងដល់ខ្ញុំ។ ខ្ញុំជឿថាព្រះអង្គស្តាប់ខ្ញុំ នៅរាល់ពេលដែលខ្ញុំអធិដ្ឋានទូលសុំទៅរកព្រះអង្គ។

លោកអភិបាល ក៏បានរំឭកគ្រីស្តបរិស័ទអំពីសកម្មភាពផ្សេងៗ ដែលគ្រីស្តបរិស័ទត្រូវប្រព្រឹត្ត នៅក្នុងឱកាសរដូវត្រណមនេះ គឺអធិដ្ឋានតមអាហារ និងចែកទានដល់អ្នកក្រីក្រ។ សកម្មភាពទាំងនេះ ជាសក្ខីភាពបញ្ជាក់ឲ្យឃើញ ពីសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះបងប្អូនដែលក្រីក្រទាំងអស់៕

**ដោយឡុង សម្ផស្ស**

# ប្រជុំគណៈកម្មការកម្មវិធីយុវជនសម្រាប់២០១៥



លោក ហ្វ្រង់ស័រ អេមេដាល្យ កំពុងប្រជុំគណៈកម្មការកម្មវិធីយុវជន។ ៉ារី

គណៈកម្មការ កម្មវិធីយុវជន ភូមិភាគកំពង់ចាម បានប្រជុំដើម្បីរៀបចំសកម្មភាព សម្រាប់ក្រុមយុវជន ភូមិភាគសម្រាប់ឆ្នាំ ២០១៥នេះ កាលពីសៀលថ្ងៃទី ២២កុម្ភៈ កន្លងទៅ នៅព្រះសហគមន៍ កាតូលិកកំពង់ចាមក្រុង ដែលមានការចូលរួមពីគណៈ-កម្មការយុវជន យុវជន-នារី និងលោកបូជាចារ្យសរុបប្រមាណជា១៤នាក់ ។

កិច្ចប្រជុំនេះ បានដាក់ផែនការសកម្មភាពលើកម្មវិធីដូចជា សន្និបាតភូមិភាគ និង សិក្ខាសាលាតាមតំបន់ ពិធីសំណាក់ធម៌ ការរៀនអំពីជីវិតសន្តៈសន្តី ដំណើរបូជនីយសក់ប្រចាំឆ្នាំ ដើម្បីជំនឿ កម្មវិធីចែកបទពិសោធន៍គ្នាទៅវិញទៅមក កម្មវិធីការ៉ូល និង សេដ្ឋាដែលស្តីអំពីទំនាក់ទំនង និង ផ្លូវភេទរវាងបុរស និងស្ត្រីកម្មវិធីរៀនបំប៉នពេលវិស្សមកាល ថ្នាក់ភាសាអង់គ្លេស កុំព្យូទ័រ និង រៀនស្ពានសន្តិភាពផងដែរ។

លោក ហ្វ្រង់ស័រ អេមេដាល្យជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង និង ជាប្រធានគណៈកម្មការកម្មវិធីយុវជន ភូមិភាគកំពង់ចាមផ្ទាល់ឲ្យដឹងថា សកម្មភាពយុវជន នៃព្រះសហគមន៍កាតូលិកក្នុងឆ្នាំថ្មីនេះនឹងផ្តោតសំខាន់លើការជួយឲ្យយុវជនខ្មែរទាំងអស់ ចេះរកអត្ថន័យនៃជីវិតរបស់គេម្នាក់ៗក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ ឲ្យចេះមានទំនួលខុសត្រូវលើខ្លួនឯង និង ចេះរិះគិត ពីអនាគតរបស់ពួកគេម្នាក់ៗ ហើយជាពិសេសនោះគឺ ឲ្យពួកគាត់ទាំងអស់គ្នាស្គាល់ ពីព្រះយេស៊ូកាន់តែច្បាស់ផងដែរ។

លោកបូជាចារ្យរូបនេះបានបន្ថែមថា ក្នុងកិច្ចប្រជុំនេះ គណៈកម្មការបានធ្វើគម្រោង និងរៀបចំសកម្មភាពយុវជនថ្មីក្នុងឆ្នាំថ្មីនេះ ហើយក៏និងពិភាក្សាគ្នារកគំនិតថ្មីៗជាច្រើនទៀតសម្រាប់ឲ្យកម្មវិធីយុវជនរីកចំរើនទៅមុខបន្ថែមទៀត។

កម្មវិធីយុវជន របស់ព្រះសហគមន៍ភូមិភាគកំពង់ចាម បានរៀបចំបង្កើតឡើង ក្នុងឆ្នាំ ២០០៧ ដែលមានយុវជន ចូលរួមតាមព្រះសហគមន៍នានាក្នុងខេត្តចំនួន៨ គឺ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ព្រៃវែង និង ស្វាយរៀង ដែលមានយុវជនសរុបប្រមាណជាង៦០០នាក់៕

**ដោយហេង៉ារី**

# យុវជនរិះគិតអំពីទុក្ខលំបាករបស់ខ្លួន

យុវជន ប្រមាណជា ១០០នាក់ មកពីព្រះសហគមន៍កាតូលិកផ្សេងៗគ្នា នៃភូមិភាគកំពង់ចាម បានមកចូលរួមក្នុងពិធីសំណាក់ធម៌ ក្រោមប្រធានបទ ៖ "ទុក្ខលំបាករបស់ព្រះយេស៊ូ និងទុក្ខលំបាករបស់ខ្ញុំ" ដែលធ្វើឡើងកាលពីថ្ងៃទី ០៣ កុម្ភៈកន្លងទៅ នៅព្រះសហគមន៍កាតូលិកព្រៃវែង ស្ថិតនៅភូមិទី៤ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង។

លោក ហ្វ្រង់ស័រ អេមេល្យដាលជាបូជាចារ្យទទួលខុសត្រូវ យុវជនភូមិភាគកំពង់ចាម បានឲ្យដឹងថា ៖ ដោយជិតដល់ រដូវសែសិបថ្ងៃ របស់ព្រះសហគមន៍កាតូលិកផងនោះ ព្រះសហគមន៍ចង់ឲ្យយុវជន ស្វែងយល់ពីសេចក្តីស្រលាញ់ដ៏ធំធេងរបស់ព្រះយេស៊ូមកយើងទាំងអស់គ្នា ដោយហ៊ានបូជាជីវិត ព្រះអង្គផ្ទាល់សម្រាប់យើងទាំងអស់គ្នា ថែមទៀតផង។ ហើយទុក្ខលំបាករបស់ព្រះយេស៊ូ គឺជាកំលាំងរបស់យើង ហើយឲ្យយុវជនជឿថា ព្រះអង្គពិតជាគង់នៅជាមួយយើងជារៀងរាល់ថ្ងៃមែន។ លោកបន្តថា នៅពេលមានទុក្ខលំបាកយុវជនត្រូវចេះប្រឈមមុខ និង ដោយមានសង្ឃឹមយ៉ាងរឹងមាំថា ព្រះយេស៊ូនៅក្បែរយើង និងចាំជួយលើកទឹកចិត្តយើងគ្រប់ពេលវេលា និង គ្រប់កាលៈទេសទាំងអស់។

ក្នុងពិធីសំណាក់ធម៌នេះ មានការអធិដ្ឋានខ្លីជាមួយគ្នា មើលរឿងអំពីជីវិតព្រះយេស៊ូរងទុក្ខលំបាក និង រិះគិតអំពីសំណួរមួយចំនួន រួមទាំងចែករំលែកបទពិសោធន៍ ដល់គ្នាទៅវិញទៅមកផងដែរ។

យុវនារី លីម បុប្ផា មកពីព្រះសហគមន៍កាតូលិកកំពង់ចាមក្រុងបានឲ្យដឹងថា ៖ សំណាក់ធម៌នេះបានជួយដាស់តឿនគាត់បានរិះគិត និងត្រៀមខ្លួន សម្រាប់ទទួលព្រះយេស៊ូ ក្នុងឱកាសបុណ្យចម្លងនាពេលខាងមុខ ក៏ដូចជាទុក្ខលំបាកនានាដែលនាងនឹងជួបប្រទះផងដែរ ដោយយកព្រះយេស៊ូជាទីពឹង។ បុប្ផាបន្តថា ទន្ទឹមនឹងការរិះគិតនេះ គាត់ក៏បានត្រៀមខ្លួនលើកលែងទោស ដល់អ្នកដែលបានធ្វើខុសចំពោះគាត់ពីមុន ហើយគាត់នឹងយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រឲ្យបានច្រើន និងព្យាយាមអត់ធ្មត់ឲ្យបានច្រើនចំពោះបញ្ហាផ្សេងៗ ដែលនឹងកើតមានឡើងចំពោះគាត់នាពេលខាងមុខ។



លោក ហ្វ្រង់ស័រ អេមេល្យដាលកំពុងចែករំលែកបទពិសោធន៍ជាមួយបងប្អូនគ្រីសបរិស័ទនៅព្រះសហគមន៍កាតូលិកកំពង់ចាម។ រូបថតៈ ហេង៉ារី

យុវជន បឿន តៃហ៊ា មកពីព្រះសហគមន៍កាតូលិកចំឡាក់ បាននិយាយថា៖ សំណាក់ធម៌បានធ្វើឲ្យគាត់ចាប់ផ្តើមនឹកឃើញ អំពីរឿងពីអតីតកាលគ្រួសាររបស់គាត់ កាលពីមុន ដែលគ្រួសារមានជីវភាពក្រលំបាក និង ឪពុកម្តាយទាស់ទែងគ្នាជាប្រចាំ និង ទទួលរងការមើលងាយ ពីសំណាក់អ្នកជិតខាង និងមិត្តភក្តិរបស់គាត់ជាច្រើន ដោសារភាពក្រីក្រ ។ គាត់បន្ថែមថា គាត់បានមើលរឿងអំពីជីវិតព្រះយេស៊ូ និងមានការចែកបទពិសោធន៍អំពីជីវិត ជាមួយក្រុមរបស់គាត់ក្នុងពេលសំណាក់ធម៌នោះ ពិតជាធ្វើឲ្យគាត់ ទទួលអារម្មណ៍ថាគាត់ពិតជាកំពុងរស់នៅជាមួយគ្រួសារធំល្អមួយ និង កំពុងទទួលកម្លាំងពីព្រះយេស៊ូ និងមានសង្ឃឹមជានិច្ចក្នុងជីវិតរបស់គាត់។

ក្នុងពិធីសំណាក់ធម៌នោះ មានយុវជន-នារី ចំនួន១០០នាក់ មកពីព្រះសហគមន៍កាតូលិកចំនួន ៥ គឺព្រះសហគមន៍កាតូលិក កំពង់ចាមក្រុង ភូមិថ្មី រលៀក ចំឡាក់ និង ព្រះសហគមន៍កាតូលិកព្រៃវែង៕

# បេក្ខជនចំនួន១៤២រូបទទួលពិធីត្រាស់ហៅយ៉ាងឱឡារិក ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក



បេក្ខជនបេក្ខនារីទទួលពិធីត្រាស់ហៅយ៉ាងឱឡារិកពីលោកអភិបាលអូលីវីយេ។ រូបថតៈ សុធីរិទ្ធិ

បេក្ខជនចំនួន ១៤២ នាក់ មកពីតំបន់ផ្សេងៗគ្នា ក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បាទទួលពិធីត្រាស់ហៅយ៉ាងឱឡារិក ក្រោមអធិបតីភាពរបស់លោក អូលីវីយេ ដ្មឺតហាស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភ្នំពេញ ដើម្បីរៀបចំខ្លួន ទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងខាងមុខនេះ ។

ពិធីនេះបានប្រព្រឹត្តយ៉ាងឱឡារិកនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច រាជធានីភ្នំពេញ និងមានការចូលរួមពីលោកអភិបាលអេមីល ដេតម្ប និងគ្រីស្តបរិស័ទ ប្រមាណជាង ១០០០ នាក់នៅថ្ងៃទី២២ កុម្ភៈ ។

បន្ទាប់ពីចំរៀងពេលចូល លោកបូជាចារ្យ ប៉ូលរឿង ឆ័ត្រសិរី តំណាងគ្រូអប់រំជំនឿ បានផ្តល់សក្ខីភាពបញ្ជាក់ពីការយកចិត្តទុកដាក់ របស់បេក្ខជន ក្នុងការទទួលអប់រំជំនឿ និងមានចិត្តតស៊ូ ក្នុងដំណើរផ្លូវយ៉ាងយូរក្នុងការត្រៀមខ្លួនយ៉ាងនេះថា បេក្ខភាពទាំង១៤២នេះ មានជំនឿគ្រប់គ្រាន់ល្មម តាមរយៈសកម្មភាពចូលរួមក្នុងព្រះសហគមន៍ ក៏ដូចជាសង្គម។ ហេតុលោកស្នើរសុំលោកអភិបាលធ្វើពិធីត្រាស់ហៅ ពួកគេយ៉ាងឱឡារិក ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក។

ក្នុងធម្មទេសនា លោកអភិបាល អលីវីយេ បានមានប្រសាសន៍ទៅកាន់បងប្អូនបេក្ខជនទាំង ១៤២ រូបថា ៖ បងប្អូនលែងទៅជា អ្នកអង្គុយមើលព្រះកាយព្រះគ្រីស្តទៀតហើយ តែគឺជាសមាជិក នៃព្រះកាយព្រះគ្រីស្តតែម្តងដោយរួមជាមួយគ្រីស្តបរិស័ទទាំងឡាយ ដែលមានព្រះគ្រីស្តជាសិរសា។

ក្នុងរដូវអប់រំពិសេសនេះ លោកអភិបាល ក៏បានរំឭកគ្រីស្តបរិស័ទទាំងអស់ដែលចូលរួមក្នុងពិធីនេះយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូល និង អនុវត្តតាម ហើយរស់ជាមួយបងប្អូនឯទៀតដូចបងប្អូនបង្កើត ក្នុងព្រះកាយព្រះគ្រីស្ត។ លោកបានបន្ថែមថា ៤០ថ្ងៃជាពេលវេលាកែប្រែ ចិត្តគំនិតប្រកាសពីព្រះរាជ្យរបស់ព្រះជាម្ចាស់ តាមរយៈការរស់នៅប្រចាំថ្ងៃរបស់យើង និងការអធិដ្ឋាន និងយើងត្រូវនាំមនុស្សឲ្យទទួលស្គាល់ថា ជីវិតមានតម្លៃថ្លៃថ្នូរ ដោយសារយើង ជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងជាបងប្អូនបង្កើតនឹងគ្នា និងយើងមានឪពុកជាព្រះជាម្ចាស់ស្រឡាញ់ និងថែទាំយើង។។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គ្មានព្រំដែន គឺសម្រាប់មនុស្សទាំងអស់។ ដូចនេះ សូមយើងយកចិត្តទុកដាក់ដល់បងប្អូន ដែលត្រូវគេជិះនៅក្នុងសង្គម ។

លោកបន្តថា ពេលយើងទទួលជ្រមុជទឹកក្នុងនាមព្រះយេស៊ូ ជាព្រះបុត្រា ជាពេលវាលា ដែលយើងចូលក្នុងព្រះសហគមន៍កាតូលិក ដែលជាគ្រួសារថ្មី និងយើងជាបងប្អូនបង្កើត។ ដូចព្រះយេស៊ូមានព្រះបន្ទូលឲ្យយើងស្រឡាញ់គ្នា ទៅវិញទៅមក ឲ្យដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ យើងទទួលជ្រមុជទឹក ដោយមាន ព្រះវិញ្ញាណដ៏វិសុទ្ធ យើងទៅជំណាក់របស់ព្រះជាម្ចាស់ នៅក្នុងខ្លួនយើង ម្នាក់ៗ ដោយមានដង្ហើម របស់ព្រះជាម្ចាស់គ្រប់ពេលវេលានៅក្នុងជីវិតរបស់យើង នាំឲ្យយើងមើលមនុស្សឯទៀតៗ តាមរបៀបថ្មី គឺវត្តមានរបស់ព្រះជាម្ចាស់ក្នុងគេ ព្រោះមនុស្សទាំងអស់មានតម្លៃ សេចក្តីថ្លៃថ្នូរ ដ៏សក្ការៈ ដោយមានព្រះជាម្ចាសគង់នៅក្នុងខ្លួនគេ ។

បន្ទាប់ពីធម្មទេសនា លោកអភិបាល បានត្រាស់ហៅបេក្ខជនទាំងអស់តាមឈ្មោះរបស់គេម្នាក់ៗ ឲ្យចុះឈ្មោះក្នុងបញ្ជី ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងពេលបុណ្យចម្លងខាងមុខ។

ប្រទេសកម្ពុជា មានប្រជាជនជាង ១៥លាននាក់មាន៩៥% ជាអ្នកប្រតិបត្តិតាមជំនឿពុទ្ធសាសនាថេរវាទ ។ កម្ពុជាជាប្រទេសមួយនៅក្នុងចំណោមប្រទេសក្រីក្រនៅឡើយ។ ប្រជាជនជាច្រើនរស់ក្នុងភាពក្រីក្រ ខ្វះការទទួលអប់រំចំណេះដឹង សេវាសុខភាពសេវាសាធារណៈ ក្នុងការទ្រទ្រង់សុមាលភាពសង្គម។ ព្រះសហគមន៍កាតូលិកនៅកម្ពុជា បានខិតខំប្រកាសដំណឹងល្អ តាមរយៈការយកចិត្តទុកដាក់ រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងការរស់នៅប្រចាំថ្ងៃដោយបម្រើអ្នកក្រីក្រ អ្នកជំងឺ មនុស្សដែលគេបោះបង់ចោល ។ល។

លោក គៀង វុឌ្ឍី ជាបេក្ខជនមកពីព្រះសហគមន៍បឹងទំពុន ក្នុងក្រុងភ្នំពេញ និង ជាបុគ្គលិក នៃអង្គការម៉ារីណុលកម្ពុជា បានរៀបរាប់ថាលោកចាប់អារម្មណ៍អំពីគ្រីស្តសាសនា នៅពេលលោកមកបម្រើការងារ ជាមួយអង្គការមារីណុលកម្ពុជាក្នុង២០០៣ តែមិនទាន់ចូលទេ។ លោកសង្កេតពីទង្វើរ របស់សាសនទូតមួយចំនួនដែលបម្រើមនុស្ស មិនរើសអើង និងមិនប្រកាន់ខ្លួន ទោះបីដឹងថា អ្នកផ្ទុះមេរោគអេដស៍សង្គមបោះបង់ចោល។ គេបម្រើយ៉ាងជិតស្និទ្ធ និងផ្តល់ភាពកក់ក្តៅដល់អ្នកជំងឺទាំងនោះ ដូចគ្រួសារតែមួយ ដោយគ្មានភាពរើសអើងជាតិសាសន៍ និង សាសនា និង មិនខ្ពើមរអើមអ្នកជំងឺណាម្នាក់ឡើយ។ មិនតែប៉ុណ្ណោះពួកគាត់តែងតែលើកទឹកចិត្តដល់អ្នកជំងឺ និងបុគ្គលិកទាំងអស់ ដោយសេចក្តីស្រឡាញ់ និងណែនាំឲ្យមានក្តីសង្ឃឹមជានិច្ច។ លោក វុឌ្ឍី បន្ត ៖ "គឺរហូតដល់ឆ្នាំ២០១២ ទើបខ្ញុំទទួលអប់រំជំនឿពេញលេញ"។ ពេលនេះ ត្រៀមខ្លួនទទួលជ្រមុជទឹកក្នុងពេលខាងមុខ។

ចំណែកយុវជន សឿម ប៊ុន ហេន បេក្ខជនមកពីព្រះសហគមន៍កាតូលិកសន្តប៉ូល ក្នុងខេត្តតាកែវ បានប្រាប់អ្នកយកព័ត៌មានអ្នកនាំសារថា លោកជាកូនក្នុងក្រុមគ្រួសារពុទ្ធបរិស័ទ នៅក្នុងភូមិ មានតែលោកមួយដែលបានប្តូរជំនឿមកតាមព្រះយេស៊ូ។ យុវជនវ័យ ២២ ឆ្នាំរូបនេះបន្តថា ការផ្លាស់ប្តូរសាសនា មិនមែនងាយស្រួលទេ ក្នុងភូមិគេរិះគន់ថា នឹងមិនគោរពឪពុកម្តាយទេពេលអនាគត់ ភ្លេចសាសន៍ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះអ្នកភូមិក៏បានរិះគន់ឪពុកម្តាយរបស់លោកដែរ ដែលបាន បណ្តោយឲ្យលោកចូលព្រះសហគមន៍កាតូលិក។

ទោះបីមានការរិះគន់ យុវជនរូបនេះនៅតែបន្ត ទទួលការអប់រំជំនឿ ចូលរួមអធិដ្ឋាន ជាងនេះលោកបន្តគោរពអ្នកភូមិ ដែលរិះគន់លោក គោរពឪពុកម្តាយ ស្រឡាញ់អ្នកភូមិទ្វេរដង ដើរសួរសុខទុក្ខដោយមិនប្រកាន់ឡើយ។ រយៈពេលប៉ុន្មានឆ្នាំនេះ អ្នកភូមិមិនរើសអើងលោកទេ គឺចូលចិត្តលោកវិញ។ នេះព្រោះតែជំនឿលើព្រះយេស៊ូដែលជំរុញលោកឲ្យអនុវត្តទ្វេរដង ក្នុងការស្រឡាញ់បងប្អូន។

ព្រះសហកមន៍ កាតូលិកភូមិភាគភ្នំពេញគ្រប់ដណ្តប់លើ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ កំពង់ស្ពឺ កំពត ព្រះសីហនុ កោះកុង និងខេត្តកែប។ មានគ្រីស្តបរិស័ទប្រមាណជាង ១៣០០០ នាក់។ ក្នុងមួយឆ្នាំៗ មានមនុស្សពេញវ័យចំនួនជិត២០០ នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក ។ ក្នុងឆ្នាំ២០១៥ នេះនឹងមានមនុស្សពេញវ័យជាង១៦០នាក់ ទទួលអគ្គសញ្ញា ជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងខាងមុខនេះ ដោយមិនរាប់បញ្ចូលចំនួនកូនង៉ែត និងកុមារ ដែលទទួលជ្រមុជទឹកទេ៕

**ដោយដាលីស**

# សាលាជេស្វីតកំពុងដំណើរការសាងសង់ក្នុងទឹកដីខេត្តបន្ទាយមានជ័យ



លោកអភិបាលគីគេ និងព្រះសង្ឃប្រោះទឹកព្រះពរលើគ្រឹះអាគារសាលាជេស្វីតសន្តសាវីយ៉េ។ រូបថតៈ សហការី

ក្រុមគ្រួសារ សហជីវិនព្រះយេស៊ូ នៅកម្ពុជា តាមរយៈអង្គការមេត្តាករុណា (ជេស្វីតសឺវីស) បានដំណើរការគម្រោងបង្កើត សាលាអប់រំចំណេះទូទៅ ដែលមានឈ្មោះថា សាលាជេស្វីតសន្តសាវីយ៉េ ដែលស្ថិតនៅភូមិភ្នំបាក់ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។

លោកបូជាចារ្យ អ៊ីវ៉ាន់ យ៉ូហាន អាស្លី ជាអគ្គនាយកគម្រោង នៃសាលាជេស្វីតសន្តសាវីយ៉េ បានរៀបរាប់ថាគម្រោងសាលានេះបានទទួលការអនុញ្ញាត ពីលោកអភិបាលគីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ឲ្យដំណើរការក្នុងភូមិភាគបាត់ដំបង តែមិនមែនជាគម្រោងការរបស់ ព្រះសហគមន៍កាតូលិកភូមិបាត់ដំបងទេ។ វាជាគម្រោងថ្មីមួយ ដែលមានគោលដៅលើកកម្ពស់គុណភាពអប់រំ សម្រាប់យុវជននៅកម្ពុជា និងចូលរួមបម្រើបេសកកម្ម របស់ព្រះសហគមន៍កាតូលិកនៅកម្ពុជាដែរ។ លោកបន្តថាការគាំទ្រពីសំណាក់លោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីភូមិភាគគឺមានសារៈសំខាន់ណាស់ ។

លោកបូជាចារ្យ អ៊ីវ៉ាន់ យ៉ូហាន អាស្លី បានមានប្រសាសន៍ទៀតថា សាលានេះ មានគម្រោងចង់បណ្ដុះបណ្ដាល និងអប់រំយុវជន និងគ្រូបង្រៀនឲ្យត្រូវ តាមគរុកោសល្យថ្មី និងជួយដល់ការលូតលាស់ នៃគំនិត និង បំនិនជីវិតផងដែរ។ លោកបូជាចារ្យយ៉ូហាន អាស្លីឲ្យដឹងថា "គឺយើងធ្វើឲ្យការរៀនសូត្រ របៀបប្រពៃណីក្នុងសាលាខ្មែរផ្លាស់ប្ដូរ ដែលយើងធ្លាប់លឺតាមគ្រូ កត់តាមគ្រូ សូត្រមេរៀន ហើយប្រលងដោយ ការទន្ទេញចាំនោះឃើញថា វាអត់ជួយឲ្យបញ្ញារីកចម្រើនទេ។ គេអាចអនុវត្តតាមគំរូទាំងនោះ យ៉ាងល្អិតល្អន់បាន ប៉ុន្តែបង្កើតដំណោះស្រាយផ្សេង ពីអ្វីដែលគេស្ដាប់ពីគ្រូនោះពិបាក។សូម្បីតែអ្នកវិទ្យាសាស្រ្ត រៀនធ្វើជាគ្រូពេទ្យក៏រៀនតាមរបៀបនេះអត់ធ្វើឲ្យប្រាជ្ញាលូតលាស់តាមដែលអាចលូតលាស់បាន។ សូម្បីតែពេលខ្ញុំបង្រៀនគណិតក៏ដូចគ្នា បើយើងចង់មានសម្រាយបញ្ជាក់ថ្មីតាមរបៀបមួយទៀត ដែលយើងអត់បានបង្រៀនគឺកម្រមានអ្នកដែលធ្វើបាន។ តែយើងគិតថា តាមគរុកោសល្យរបស់យើង អាចជួយបែបនោះបាន។ ហើយយើងចង់ (ធ្វើ) មួយទៀត គឺបង្រៀនគរុកោសល្យរបៀបថ្មីនេះនៅទូទាំងប្រទេស"។

គម្រោងសាលា ជេស្វីតសន្តសាវីយ៉េ របស់អង្គការមេត្តាករុណា មានបួនផ្នែកគឺ មណ្ឌលសិក្សាសហគមន៍ សាលាបឋម សាលាមធ្យម និង មណ្ឌលអភិវឌ្ឍធនធានគ្រូ។ ហើយក្នុងពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលបានយល់ព្រមឲ្យមានការសាងសង់អាគារដើម្បីប្រតិបត្តិការសកម្មភាព របស់អង្គការនេះ ហើយកាលពីពាក់កណ្ដាលឆ្នាំ២០១៤ ដោយមានសុពលភាពរយៈពេល៥ឆ្នាំ។

ទោះបីជាអាគារមិនទាន់មាន នៅឡើយ តែសកម្មភាពមួយចំនួនរបស់សាលាជេស្វីតសន្តសាវីយ៉េ បានលេចចេញជារូបរាងបណ្ដើរៗ ក្នុងពេលកន្លងមក គឺមានកម្មវិធីមណ្ឌលសិក្សាសហគមន៍។ លោកបូជាចារ្យយ៉ូហាន អាស្លី បានបន្តថា "យើងមានសកម្មភាពគឺមានបង្រៀនបំប៉នពេលវិស្សមកាល (summer school) កាលពីឆ្នាំទៅ សម្រាប់ប្អូនៗ រៀនថ្នាក់ទី៦ ដែលឆ្លងចូលថ្នាក់ទី៧។ យើងធ្វើនៅបួនសាលា ដែលនៅជិតតំបន់របស់យើង ហើយយើងបានរៀបចំសកម្មភាពសិក្សាជាមួយពួកគេ។ យើងក៏បានរៀបចំជ្រើសរើស គ្រូពីសាលាទាំងនោះ (ដើម្បីបង្រៀន) គឺយើងធ្វើហើយ។ យើងទទួល (គ្រប់គ្រង) សាលាមត្តេយ្យ នៅជីឡូត៏រយៈពេល ២ឆ្នាំ។ យើងបង្រៀនអង់គ្លេសក្មេងៗ នៅសាលាមត្តេយ្យនៅភ្នំបាក់ និង បាននយ។ ហើយខ្ញុំបង្រៀនគណិតវិទ្យា នៅសាលាគរុកោសល្យគ្រូបឋម នៅខេត្តបន្ទាយមានជ័យ។ យើងបង្កើតសកម្មភាពតូចៗបែបនេះ ដើម្បីឲ្យគេស្គាល់យើង និងយើងស្គាល់គេ។ ហើយនៅពេលយើងបើកមណ្ឌលគឺនឹងមានដំណើរការស្រួល"។

តាមការរៀបរាប់ របស់លោកបូជាចារ្យ យ៉ូហាន អាស្លី សាលាជេស្វីតសន្តសាវីយ៉េនេះ នឹងបើកទទួលសិស្សនៅពាក់កណ្ដាលឆ្នាំ២០១៥ ខាងមុខនេះ ដោយចាប់ផ្ដើមលើផ្នែកសិក្សាសហគមន៍។ លោកបូជាចារ្យ ឲ្យដឹងថា "មណ្ឌលសិក្សាសហគមន៍ អាចដើរតួនាទី២ គឺមណ្ឌលសិក្សាក្រៅប្រព័ន្ធ និងមណ្ឌលអភិវឌ្ឍធនធានគ្រូ។ មណ្ឌលសិក្សាក្រៅប្រព័ន្ធគឺជាកន្លែងជួយប្អូនៗរៀនក្រៅប្រព័ន្ធ សម្រាប់អ្នកដែលឈប់រៀន និងចង់ឈប់រៀន ឬចង់រៀនបន្ថែម ដែលនៅតែបន្តចូលរៀន។ កម្មវិធីនេះមិនប៉ះពាល់ដល់កម្មវិធីរដ្ឋទេ។ នៅសាលារដ្ឋ គេនៅតែរៀននៅទីនោះដដែល។ យើងនឹងមានបង្រៀន កាត់ដេរមួយខែដំបូង ដើម្បីឲ្យអ្នកចង់ធ្វើការ នៅរោងចក្រថៃក្បែរនោះអាចធ្វើការបាន។ យើងនឹងធ្វើការទំនាក់ទំនង ជាមួយរោងចក្រថៃនៅទីនោះ ដើម្បីបញ្ជូនកម្មករឲ្យគេ ព្រោះគេពិបាករកកម្មករ និងមានកន្លែងច្រើន ដែលពិបាករកកម្មករ។ ហើយ (យើង) ចង់ធ្វើជាអ្នកផ្សាភ្ជាប់ទំនាក់ទំនងនេះ តាមដែលអាចធ្វើទៅបាន"។

លោកយ៉ូហាន អាស្លី បន្តថា រីឯមណ្ឌលអភិវឌ្ឍន៍ធនធានគ្រូវិញ គឺកន្លែងមួយ រៀបចំវគ្គសិក្សាបន្ថែមសម្រាប់បណ្ដុះបណ្ដាលគរុកោសល្យរបស់គ្រូ ដែលមានក្របខ័ណ្ឌរដ្ឋរួចហើយ។ ហើយជាជំហានដំបូងកម្មវិធីនេះ នឹងចាប់ផ្ដើមនៅខែសីហាខាងមុខនេះ ជាមួយគ្រូបឋមសិក្សាដែលជាគ្រូរបស់អង្គការជេស្វីត និង បន្តបន្ទាប់មក ជាមួយគ្រូនៅតាមសាលារដ្ឋនានាក្នុងខេត្តបន្ទាយមានជ័យ ។ លោកយ៉ូហាន អាស្លីបន្ថែមថា "ក្នុងវគ្គនីមួយៗ យើងអាចមានជាសំភារៈឧបទេសដើម្បីជួយដល់គ្រូ ប៉ុន្តែយើងគ្មានប្រាក់ ដើម្បីឧបត្ថម្ភគ្រូឡើយ ។ សម្រាប់ការបណ្ដុះបណ្ដាលនេះ យើងនឹងធ្វើជាជំហានៗពីបឋម ទៅមធ្យមសិក្សា ហើយក៏ធ្វើតាមខេត្តនីមួយៗ ដែលមានបង្រៀន គរុកោសល្យដែរ ប៉ុន្តែដំបូង យើងធ្វើនៅក្នុងខេត្តបន្ទាយមានជ័យនេះសិន"។

លោកបានបញ្ជាក់ទៀតថាចំពោះកម្មវិធីផ្សេងៗទៀត នឹងត្រូវបានរៀបចំក្នុងពេលបន្តបន្ទាប់គ្នា ក្រោយពេលដំណើរការការងារ នៃផ្នែកនេះបានទទួលជោគជ័យ។

ហើយកាលពីថ្ងៃទី ២៩ ខែមករា ២០១៥នេះ លោកអភិបាលគីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានធ្វើពិធីបាចទឹកព្រះពរលើដី និង គ្រឹះសាងសង់អាគារ តាមជំនឿរបស់ព្រះសហគមន៍កាតូលិក និងមានអ្នកចូលរួមពីខាងមន្ទីរអប់រំផងដែរ៕

**ដោយ កែវ កញ្ញា**

# លោកអភិបាល ប៉ូល ទេព អ៊ឹមសុត្ថា លោកអភិបាលភូមិភាគបាត់ដំបង



លោក ប៉ូលទេព អ៊ឹមសុត្ថា កើតនៅឆ្នាំ ១៩៣៤។ លោកជាកូនរបស់គិលានុបដ្ឋាក ជនជាតិខ្មែរ មិនមែនកាតូលិក ប៉ុន្តែម្តាយជាកាតូលិកកូនកាត់វៀតណាម - បារាំងសញ្ជាតិបារាំង។ លោកសិក្សានៅបឋមសិក្សានៅក្រុងសៃងន់ (អាណាម) ប្រទេសវៀតណាម។

នៅឆ្នាំ ១៩៤៧ លោកចូលកម្មវិធីបោះជំរំធំ របស់ក្រុមកុមារកាយឫទ្ធិអន្តរជាតិ នៅក្រុងម័រសង់ (Moissan) នៅពេលនោះ លោកប្រាប់ថា "ខ្ញុំប្រាថ្នាចង់ធ្វើជាបូជាចារ្យ" ក្រោយមកលោកចូលរៀនអនុទេវវិទ្យាល័យសាំងរ៉ូក (St.Roch) នាក្រុង ម៉ុងប៉ុលីយេ (Montpellier) ប្រទេសបារាំង ដើម្បីរៀបចំជាបូជាចារ្យ រហូតដល់ចប់ថ្នាក់វិទ្យាល័យ។ លោកបានជួបសិស្សច្បង គឺលោក ស៊ីម៉ុង ឆែមយ៉េន (Chhem Yen) ដែលកូនសិស្សរៀនទីនោះមុនលោក។ ពេលលោកអាយុ ១៨ ឆ្នាំ ដែលលោកមានសិទ្ធិជ្រើសរើសសញ្ជាតិលោកសម្រេចចិត្តជ្រើសរើសសញ្ជាតិខ្មែរ ដែលខុសពីបងប្អូនគាត់ទាំងអស់ ព្រោះពួកគេជ្រើសរើសសញ្ជាតិបារាំង។ ក្រោយមក លោករៀនថ្នាក់ទស្សនវិជ្ជា និងទេវវិទ្យានៅទេវវិទ្យាល័យ ជិតទីក្រុងប៉ារីស នៅអីស៊ី លេមូលីណូ (d'Issy les Moulineaux)។ លោកទទួលការតែងតាំងនៅវិសាលវិហារ នាទីក្រុងប៉ារីស ឆ្នាំ១៩៥៩។ លោកជាបូជាចារ្យខ្មែរទីពីរ បន្ទាប់ពីលោក ឆែមយ៉េន ដែលជា លោកខ្មែរទីមួយ។ លោកបន្តការសិក្សាទេវវិទ្យា ក្រោយតែងតាំង នៅមហាវិទ្យាល័យអង់ហ្សេលីគូម (Angelicum) នៅទីក្រុងរ៉ូម ហើយរៀនរហូតដល់ចប់ថ្នាក់បណ្ឌិតលើសារណាខាងទេវវិទ្យា ដែលមានឈ្មោះថា "ការរៀបរាប់ប្រវត្តិសាស្ត្រនៃបេសកកម្ម របស់ព្រះសហគមន៍កាតូលិកកម្ពុជា"។ លោកមានប្រាជ្ញាឈ្លាសវៃខាងទេវវិជ្ជា ក៏ប៉ុន្តែ លោកមានការយល់ដឹងសាសនាព្រះពុទ្ធខ្លះដែរ។

នៅខែកក្កដា ឆ្នាំ ១៩៦២ លោកត្រឡប់មកក្រុងភ្នំពេញ។ ដោយសារលោកនៅបារាំងយូរ បានជាលោកចាប់ផ្តើមទំនាក់ទំនង ជាមួយប្រជាជនខ្មែរដើម្បីយល់ដឹងសភាពការណ៍របស់ប្រទេស។ ហើយចាប់ផ្តើមមុខងារជាបូជាចារ្យ ជាគង្វាលភ្លាម នៅព្រះសហគមន៍ ហួឡាង (Hoalang) ឬហៅ ភូមិព្រះមាតា ក្រុងភ្នំពេញ។ លោកជាបូជាចារ្យជំនួយរបស់លោកកូអេឡង់។ លោកបង្កើតក្រុមសកម្មភាពកាតូលិក (Action Catholique) នៅភូមិព្រះមាតា ជាមួយក្រុមយុវជន។

នៅឆ្នាំ ១៩៦៣ លោកបង្កើតក្រុមបញ្ញវន្តមួយ ឈ្មោះ ប៉ាស រ៉ូម៉ាណា (PaxRomana) ដើម្បីរិះគិតទំនាក់ទំនងរវាងវប្បធម៌ខ្មែរ និងជំនឿគ្រីស្តបរិស័ទក្នុងបរិបទថ្មី គឺក្រោយប្រទេស កម្ពុជាទទួលឯករាជ្យ ។ សមាជិកក្នុងក្រុមនេះ មានអ្នកធំខាងនយោបាយខ្មែរ ខាងឆ្វេងចូលរួមដែរ ដូចជា លោកឈរ សេង (ដែលក្រោយមក លោកជារដ្ឋមន្ត្រីក្រសួងអប់រំ របស់សម្តេចសីហនុ) លោកគាត ឈន់ (រដ្ឋមន្ត្រីហិរញ្ញវត្ថុរបស់ខ្មែរក្រហម និងលោកហ៊ុន សែន) លោកជា សាន (ឯករាជទូតគ្រីស្តបរិស័ទរបស់សម្តេចសីហនុ) លោកវ៉ាន់មូលីវ៉ាន់ (ស្ថាបត្យករ)។ នៅពេលនោះ លោកក៏ព្យាយាមអនុវត្តគំនិត តាមរបៀបវ៉ាទីកង់ទី ២ដែរ ជាពិសេសខាងពិធីបុណ្យ។ លោកបង្រៀនទេវវិជ្ជាសច្ចធម៌ (Dogmatic Theolgy) នៅទេវវិទ្យាល័យ ក្រុងភ្នំពេញនៅឆ្នាំ ១៩៦៤។

នៅឆ្នាំ ១៩៦៥ លោកមានទំនាក់ទំនងជាមួយសាសនាព្រះពុទ្ធ ដោយសារហេតុនេះ លោកធ្វើការច្រើនដើម្បីពន្យល់ព្រះគម្ពីរ និងពិធីបុណ្យជាភាសាខ្មែរ ដោយមានជំនួយតាមរយៈមិត្តភ័ក្រ្តជាលោកសង្ឃ ព្រះពុទ្ធសាសនា។

លោកទទួលការតែងតាំង ជាលោកអភិបាល (Apostolic Prefect) របស់ភូមិភាគបាត់ដំបង នៅឆ្នាំ ១៩៦៨ ជាលោកអភិបាលលើកដំបូងសម្រាប់ភូមិភាគនេះ (អាយុ ៣៥ ឆ្នាំ)។ លោកព្យាយាមតុបតែង ព្រះវិហារ ដោយប្រើគំនូរតាមរបៀបខ្មែរ។ លោកសាងសង់ផ្ទះ លោកអភិបាល ហើយទៅគ្រប់ទីកន្លែងក្នុងភូមិភាគ។ លោកខិតខំរៀបចំរចនាសម្ពន្ធក្នុងភូមិភាគដែរ។ លោកជោគជ័យ ក្នុងការណែនាំតាមគំនិតទស្សនវិជ្ជា ឲ្យក្រុមយុវជនបញ្ញវន្ត។

ស្ថានការណ៍សង្គ្រាម របស់ប្រទេសកាន់តែពិបាក នៅខែមីនា ឆ្នាំ ១៩៧៥ ភ្នំពេញជិតធ្លាក់ក្នុងដៃរបស់ខ្មែរក្រហម ពេលនោះលោកកំពុងធ្វើដំណើរនៅតំបន់អឺរ៉ុប ប្រទេសបែល្ស៊ិក លោកនិយាយជាមួយមិត្តភ័ក្រ្តថា "ខ្ញុំនឹងទៅប្រទេសកម្ពុជាវិញ ប៉ុន្តែពីរ បីសប្តាហ៍ទៀត ខ្ញុំនឹងស្លាប់ហើយ "។ ហើយតាមពិត លោកមិនចាំបាច់មកវិញទៀតក៏បានដែរ។ គាត់មកវិញ ដោយសារគាត់គិតថា មិនអាចបោះចោលហ្វូងចៀមរបស់គាត់បានទេ!។

លោកថ្វាយអភិបូជា ចុងក្រោយ នៅបុណ្យថ្ងៃអាទិត្យ ទី ១៣ ខែមេសា ឆ្នាំ ១៩៧៥ លោកធ្វើពិធីលើកលែងទោសបាបទូទៅ ឲ្យគ្រីស្តបរិស័ទចុងក្រោយនៅក្នុងព្រះវិហារភូមិភាគបាត់ដំបង លោកមានប្រសាសន៍ថា "នេះជាលើកចុងក្រោយដែលខ្ញុំប្រសិទ្ធពរឲ្យយើង ខ្ញុំសូមលើកលែងទោសឲ្យអស់អ្នកដែលនៅទីនេះ និងឲ្យអ្នកដែលអត់មកទីនេះដែរ"។ លោកចេញទៅនៅភូមិចំណោម ដែលជាភូមិកាតូលិកជាមួយ លោក យ៉ូហាន បាដ្រេ (Jean Badre) ជាបព្វជិតបេណេឌិកទីន។

ប៉ុន្មានថ្ងៃក្រោយទៀត ដែលជាថ្ងៃចុងក្រោយនៃជីវិត លោកត្រូវទាហានឲ្យចេញពីភូមិ ជាមួយលោកបាដ្រេ និងបុរសជនជាតិ អូស្រ្តាលីម្នាក់ និងប្រពន្ធរបស់គាត់បញ្ជូនទៅសាលាស្រុកភូមិបត់ត្រង់ ដោយប្រាប់ថានឹងមានឡានមកពីភ្នំពេញនឹងជូនពួកគាត់ទៅព្រំដែនថៃ។ គាត់ទាំងអស់នៅវត្តនោះ ៥ ថ្ងៃ។ ពេលខ្មែរក្រហមជូនពួកគាត់ដល់ស្ពានមួយហៅ "ស្ពានយួន" គេក៏បាញ់សម្លាប់ទាំងបួននាក់នោះតែម្តង ប្រហែលជាថ្ងៃទី ៣ ខែឧសភា ឆ្នាំ ១៩៧៥៕



**( ម៉ាកុស ៩,២-១០ )**

ក្នុងរដូវអប់រំពិសេស អាទិត្យទី២ តាមព្រះគម្ពីរដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូបញ្ចេញរស្មីឲ្យសាវ័កឃើញ ។ ក្នុងពន្លឺរស្មី ព្រះយេស៊ូសម្ដែងខ្លួនឲ្យសាវ័កស្គាល់ព្រះអង្គ ជាព្រះពោពេញដោយសិរីរុងរឿង និងមានព្រះសូរសៀងមួយថា ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដាប់ព្រះអង្គចុះ។ ព្រះអង្គសន្ទនា ជាមួយលោក ម៉ូសេ និងព្យាការីអេលី។ សាវ័កទាំងបីហានពិសាធអំណរសប្បាយដ៏លីសលប់ក្នុងសិរីរុងរឿងរបស់ព្រះអង្គ។ លោក សិលា ទូលព្រះអង្គថា "យើងខ្ញុំនៅទីនេះប្រសើរណាស់"។ តាមអារម្មណ៍លោក សិលា ចង់នៅជាមួយព្រះអង្គ លោក ម៉ូសេ និង អេលី រហូតដោយកសាងពន្លាបី។ មនុស្សសព្វថ្ងៃនេះរកអំណរសប្បាយក្លែងក្លាយដោយប្រើគ្រឿងញៀន បំផ្លាញជីវិតខ្លួន ។ មានតែជីវិត ដែលរួមជាមួយព្រះអង្គទេដែលនាំឲ្យយើងមានអំណរសប្បាយ និងសេចក្ដីសុខ។ ពិតមែនជីវិតដែលរួមជាមួយព្រះអង្គ មានអំណរសប្បាយពិតប្រាកដ។ យើងរួមចិត្តជាមួយព្រះអង្គរាល់ថ្ងៃ ហើយស្ដាប់សំលេងព្រះអង្គ តើព្រះអង្គមានព្រះបន្ទូលមកយើងអ្វី?

**( យ៉ូហាន ២,១៣-២៥ )**

អាទិត្យទី៣នៃរដូវ អប់រំពិសេសនេះ តាមដំណឹងល្អនិយាយអំពីព្រះវិហារនៅទីក្រុងយេរូសាឡឹម ព្រះយេស៊ូបានដេញអ្នកលក់ដូរ ចេញពីព្រះវិហារ។ ប្រហែលជាពួកលក់ដូរ យកឱកាសរកស៊ីដោយលក់ដូរឲ្យគេ ដើម្បីថ្វាយយញ្ញបូជាទៅ ព្រះជាម្ចាស់នៅព្រះវិហារនោះ តាមទំលាប់របស់គេ។ តាមធម្មតា មនុស្សយើងចេះតែរកស៊ីពេលមានពិធីបុណ្យផ្សេងៗ។ ប៉ុន្តែពួកគេអត់យល់ថាព្រះវិហារជាកន្លែងដ៏វិសុទ្ធ ព្រោះជាដំណាក់របស់ព្រះជាម្ចាស់។ ប្រជាជនធ្វើឲ្យព្រះវិហារទៅជាទីផ្សារវិញ។ផ្សារគឺកន្លែងមួយដែលសំខាន់សម្រាប់រកស៊ី តែគេចេះកុហកគ្នា ចេះបោកគ្នា ខឹងគ្នា ដូច្នេះព្រះវិហារប្រែទៅជាកន្លែងមិនវិសុទ្ធ។ ព្រះអង្គបានប្រៀបធៀបរូបកាយ របស់ព្រះអង្គ ទៅនឹងព្រះវិហារ។ ដំណាក់ព្រះជាម្ចាស់ សំដៅទៅលើរូបកាយរបស់គ្រីស្តបរិស័ទយើងដែរ យើងត្រូវមានចិត្តស្អាតបរិសុទ្ធ។ *(១ករ ៦:១៩)* យើងជាដំណាក់របស់ព្រះជាម្ចាស់ ។ ពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញគង់ជាមួយយើង យើងមានទំនាក់ទំនងជាមួយព្រះបិតា។ ព្រះអង្គមកសម្អាតដំណាក់របស់ព្រះអង្គ។

**( យ៉ូហាន ៣,១៤-២១ )**

តាមអត្ថបទគម្ពីរដំណឹងល្អថ្ងៃនេះ រៀបរាប់ អំពីប្រជាជនដែលត្រូវពស់ចឹកសំឡឹងមើលទៅរូបពស់ ដែលលោក ម៉ូសេ បានធ្វើពីទងដែងនោះ មិនត្រូវស្លាប់ឡើយ។ព្រះយេស៊ូដែលជាប់លើឈើឆ្កាងប្រទានឲ្យយើងជីវិត គឺអស់អ្នក ដែលប្រែចិត្តមកជឿសង្ឃឹមលើព្រះយេស៊ូ ដែលត្រូវគេឆ្កាង អ្នកនោះនឹងទទួលការសង្គ្រោះ ពីព្រះអង្គ។ព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងណាស់ ដោយបាន ចាត់ព្រះបុត្រាយាងមកបូជាជីវិតសម្រាប់យើង ។ ព្រះអង្គបានយាងមក និងនាំពន្លឺមកជាមួយ តែមនុស្សលោកស្រឡាញ់ភាពងងឹតច្រើនជាងពន្លឺ ព្រោះអំពើរបស់គេ ជាអំពើអាក្រក់។ ជីវិតជាគ្រីស្តបរិស័ទ យើងប្រកាសជំនឿថាយើងជឿលើព្រះអង្គមែន។ជីវិតយើងនៅក្នុងពន្លឺព្រះអង្គ ហើយយើងត្រូវស្រឡាញ់ពន្លឺរបស់ព្រះអង្គ ដោយរស់នៅក្នុងពន្លឺរបស់ព្រះអង្គ។ បើយើងស្រឡាញ់ព្រះអង្គមែន យើងសប្បាយនឹងជីវិតដែលនៅក្នុងពន្លឺ របស់ព្រះអង្គ។ ព្រះឈើឆ្កាង បានសង្គ្រោះយើងហើយ។

**( យ៉ូហាន ១២,២០-៣៣ )**

ដំណឹងល្អតាមសន្តយ៉ូហាន រៀបរាប់អំពីព្រះយេស៊ូ សម្ដែងសិរីរុងរឿងឲ្យមនុស្ស គ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ។ ព្រះអង្គត្រូវសោយទិវង្គត ហើយមានព្រះជន្មរស់ឡើងវិញ ។ ព្រះយេស៊ូ ប្រៀបធៀបជីវិត ដូចជាគ្រាប់ស្រូវ ត្រូវតែធ្លាក់ដល់ដី ហើយងាប់ ដើម្បីកើតជាថ្មីហើយបង្កើតផលច្រើន។ ព្រះអង្គសព្វព្រះហឫទ័យសោយទិវង្គត សម្រាប់មនុស្សគ្រប់ជាតិសាសន៍។ គ្រីស្តបរិស័ទ មានន័យថា អ្នកដើរតាមព្រះគ្រីស្ត និងអ្នកប្រកាសដំណឹងល្អ របស់ព្រះគ្រីស្តដល់មនុស្សលោក។ យើងជាអ្នកបន្តបេសកកម្មរបស់ព្រះគ្រីស្ត ជាអ្នកប្រកាសដំណឹងល្អ។ ដំណឹងល្អត្រូវចូលនៅក្នុងវប្បធម៌មនុស្ស។ តាមពិត មនុស្សយើង ស្រឡាញ់វប្បធម៌របស់ខ្លួន ហើយគិតថាវប្បធម៌របស់ខ្លួនត្រូវជាងគេ។ ជីវិតជាអ្នកប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ ដើម្បីយើងរៀនអំពីវប្បធម៌គេ ជីវិតយើងត្រូវស្លាប់ ក្នុងវប្បធម៌របស់ខ្លួន ដើម្បីកើតនៅក្នុងវប្បធម៌គេទៀត។

**( ម៉ាកុស ១៤,១-១៥,៤៧ )**

តាមពិត អត្ថបទក្នុងអាទិត្យនេះវែងណាស់ មិនអាចពន្យល់យ៉ាងល្អិតល្អន់បានឡើយ។ ក្នុងអត្ថបទនេះរៀបរាប់អំពីព្រះយេស៊ូសោយទុក្ខ លំបាករីឯសាវ័កវិញ មានជំនឿតិច ហើយកំសាកណាស់។ យូដា បានក្បត់ព្រះយេស៊ូ សិលា បានបដិសេធព្រះអង្គ ៣ដង និងមាននាយទាហានរ៉ូម៉ាំងទទួលស្គាល់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន។ សូមអរព្រះគុណព្រះអម្ចាស់ សម្រាប់បូជាជីវិតឲ្យយើង។យើងត្រូវរិះគិតពីព្រះបន្ទូល និងជីវិតរបស់យើងរៀងៗខ្លួន តើជីវិតយើងខ្ញុំដូចអ្នកណាខ្លះ? តើខ្ញុំមានក្បត់ព្រះយេស៊ូ ដោយអត់បានស្មោះត្រង់នឹងពួកគេ? តើខ្ញុំបានបដិសេធព្រះយេស៊ូប៉ុន្មានដង នៅចំពោះមុខគេ ជាពិសេស ខាងមុខអ្នកស្អប់គ្រីស្តសាសនា? តើខ្ញុំជឿថាព្រះអង្គពិតជាព្រះបុត្រា ដូចនាយទាហានរ៉ូម៉ាំង ឬអត់?

រៀបចំដោយ:
**លោកបូជាចារ្យ អាប្រាហាំ ខុន**

---

## កំណាព្យ

## បើសុខកាយសប្បាយចិត្តសូមគិតពី ប្រយោជន៍ជាតិយើង

( បទពាក្យ ៧ )

១-យើងជាពលរដ្ឋធំធាត់កាយ
ជីវភាពធូរធារដោយសមរម្យ
រីករាយសប្បាយក្នុងសង្គម
រស់នៅសុខក្តុំជុំគ្រួសារ។

២-មានមុខរបរគ្រប់ជាន់ថ្នាក់
បង្កើនទ្រព្យធន់ទន់គ្រួសារ
រកស៊ីឥតស្រាកប្រាំងវក្សា
ដោះស្រាយបញ្ហាដោយសុខសាន្ត។

៣-បើកភ្នែកប៉ប្រិមញញឹមស្រស់
ទ្រព្យកើនរាល់ថ្ងៃមិនដែលខាន
គ្មានអ្វីខ្វល់សោះដក់ក្នុងប្រាណ
ចិត្តនៅចង់បានបម្តទៀត។

៤-យើងជាពលរដ្ឋកំណត់ថា
ស្រឡាញ់វប្បធមិកុំបីឃ្លាត
រស់លើខេមរាទឹកដីជាតិ
ជួយប្រយោជន៍ជាតិ និងសង្គម។

៥-មានទ្រព្យគាប់ចិត្តគិតសោយសុខ
គិតរឿងផ្ទាល់ខ្លួនធ្វើជាធំ
ប្រឹងប្រែងថែទុកបរមូលផ្តុំ
អាត្មានិយមពុំរអែង។

៦-ក្រឡេកមុខក្រោយជុំវិញផង
ជាម្ចាស់ប្រទេសនៃខ្លួនឯង
សូមមានបំណងឲ្យជាក់ស្តែង
ត្រូវជួយចំបែងក្រែងបារម្មណ៍។

៧-គិតពីប្រយោជន៍ប្រទេសយើង
កុំយករួចខ្លួនពួនសង្ងំ
កំពង់រុងរឿងយ៉ាងឧត្តម
ប្រទេសជាតិធំពុំអើពើ។

៨-ចូលរួមចំណែកចែករំលែក
ដើម្បីជាតិខ្លះច្បាស់អ្នកធ្វើ
ថ្ងៃនេះឬស្អែករាល់ទង្វើរ
ភាពល្អប្រសើរមានដល់អ្នក ។

៩-ទឹកចិត្តស្មោះត្រង់លះបង់ជួយ
ពលរដ្ឋទាំងឡាយគ្រប់ជាន់ថ្នាក់
ជាតិយើងតែមួយកុំស្ទើរស្តាក់
ប្រយោជន៍ជាតិអ្នកសំខាន់ណាស់។

**និពន្ធដោយ: អ្នកស្រី ខុង ណាវី**

# រូបថតសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ



ពិធីចូលឆ្នាំបងប្អូនជនជាតិចិន និង វៀតណាម នៅព្រះសហគមន៍កាតូលិកបាត់ដំបង



ទិវានារីអន្តរជាតិ នៅសាលាមត្តេយ្យពន្លកថ្មីនៃព្រះសហគមន៍កាតូលិកបាត់ដំបង



ពិធីដើរផ្លូវព្រះឈើឆ្កាងនៅព្រះសហគមន៍កាតូលិកបាត់ដំបង




រូបថតអនុស្សាវរីយ៍ របស់សិក្ខាកាមដែលចូលរួមសំណាក់ធម៌តេហ្សេ សម្រាប់អាស៊ីអាគ្នេយ៍



អធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅនៅភ្នំពេញថ្មី



ពិធីបុណ្យរំលឹកខួបលោកបូជាចារ្យ ប៉ូយៀប



លោកអភិបាលអន់តូនីសាមីយកប្រេងក្រអូបគូសសញ្ញាឈើឆ្កាងលើដៃបេក្ខជន ដែលទទួលពិធីត្រាស់ហៅ។



សមាគមសន្តវ៉ាំងសង់ដឺប៉ូលប្រជុំប្រចាំឆ្នាំ ដើម្បីវាយតម្លៃ និងរៀបចំផែនការក្នុងឆ្នាំ២០១៥ នៅព្រះសហគមន៍ភូមិភាគកំពង់ចាម កាលពីថ្ងៃទី ៨-៩មីនា។



ក្រុមយុវជនកាតូលិកកក់សក់សំលាប់ចៃដល់កុមារតាមភូមិ។


អេម៉ាញូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | | |
|---|---|---|
| ភ្នំពេញ | : | **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : | **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : | **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : | **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : | **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : | **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : | **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

កម្មវិធីវិទ្យុ
" ខ្ញុំត្រូវការអ្នក "
ជាកម្មវិធីសម្រាប់យុវជន
ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក